ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការជាតិ ៥ឆ្នាំ

# ស្តីពី

# ការត្រួតពិនិត្យគ្រឿងញៀន

# ២០០៥-២០១០

អ.ជ.ប.គ.ញ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**

**លេខ:** ១៤៨១ សជណ.ឯក

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៤

ចូល
លេខ: 846
ថ្ងៃ: 22/12/04

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**គោរពជូន**

**ឯកឧត្តម សខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន**

**កម្មវត្ថុ :** ករណីសំណើសុំពិនិត្យ និងសំរេចលើសេចក្ដីព្រាងផែនការជាតិ៥ឆ្នាំ (២០០៥-២០១០) ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

**យោង :** - លិខិតលេខ ០១៩/០៤ លស អ.ជ.ប.គ.ញ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៤ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- ចំណាររបស់សម្ដេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៤ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ទីស្ដីការគណៈរដ្ឋមន្ត្រីសូមជំរាបជូន ឯកឧត្តមសូមមេត្តាជ្រាបថា : ចំពោះបញ្ហានេះ រាជរដ្ឋាភិបាលបានសំរេចឯកភាពតាមសេចក្ដីព្រាងផែនការជាតិ៥ឆ្នាំ (២០០៥-២០១០) ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនដែលអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនិងគ្រឿងញៀនបានស្នើមកនេះ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ស្មោះអំពីខ្ញុំបាទ ។

**ជ.ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**ប្រាក់ សុខុន**

**ចម្លងជូន :**

- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យ សម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាខេត្ត-ក្រុង
- នាយកដ្ឋាន ផ្ទៃក្នុង
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
លេខ : ០១៩/ឋ.ក/០៤ អ.ជ.ប.គ.ញ

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៤

ការប្រញាប់

សូមគោរពជូន
សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**<u>កម្មវត្ថុ</u>** : សំណើសុំពិនិត្យ និងសំរេចលើសេចក្ដីព្រាងផែនការជាតិ៥ឆ្នាំ(២០០៥-២០១០) ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយសសូមជំរាបជូនសម្ដេចនាយករដ្ឋមន្ត្រីមេត្តាជ្រាបថា សភាពការណ៍គ្រឿងញៀននៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ននេះ កំពុងមានការចរាចរនិងការប្រើបំពានគួរឱ្យព្រួយបារម្ភ ជាពិសេសនៅក្នុងស្រទាប់យុវវ័យនិងកំពុងចោទជាបញ្ហាចំពោះសង្គមជាតិទាំងមូល ។

ដើម្បីទប់ស្កាត់និងដោះស្រាយបញ្ហានេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានកសាងផែនការជាតិ៥ឆ្នាំដើម្បីកាត់បន្ថយគ្រោះថ្នាក់និងឈានទៅលុបបំបាត់ ការផលិត ការដាំដុះ ការចរាចរចែកចាយ និងការប្រើបំពានគ្រឿងញៀននៅកម្ពុជា ។

ផែនការនេះ បានទទួលការឯកភាពពីក្រសួងជាសមាជិកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងក្រសួងពាក់ព័ន្ធ នៅក្នុងសម័យប្រជុំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនលើកទី៥ កាលពីថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០០៤ ។

អាស្រ័យហេតុនេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនស្នើសុំរាជរដ្ឋាភិបាល ពិនិត្យ និងសំរេចលើផែនការជាតិ៥ឆ្នាំ(២០០៥-២០១០)ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ដើម្បីយកទៅអនុវត្ត និងដាក់បញ្ចូលទៅក្នុងកម្មវិធីស្នើសុំជំនួយពីអន្តរជាតិ ។

សូមគោរពជូនភ្ជាប់មកជាមួយនូវសៀវភៅផែនការជាតិ៥ឆ្នាំស្ដីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន១ច្បាប់ ។

សូមសម្ដេចនាយករដ្ឋមន្ត្រីមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់និងដោយស្មោះស្ម័គ្រអំពីខ្ញុំ ។

ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

sent to PM
13.12.04

ស.ខេង

# មាតិកា


សេចក្តីផ្តើម........................................A-B

I. **ជំពូកទី១ ស្ថានភាពទូទៅ**........................................២

១. ស្ថានភាពភូមិសាស្ត្រ និងប្រជាជន........................................២

១.១. ទីតាំងភូមិសាស្ត្រ........................................២

១.២. អាកាសធាតុ........................................២

១.៣. ស្ថានភាពប្រជាជន សាសនា ទំនៀមទំលាប់ប្រពៃណី........................................៣

១.៤. រចនាសម្ព័ន្ធសង្គម( ការអប់រំ សុខាភិបាល និងសេវាសង្គមផ្សេងៗ)........................................៣

២. របបនយោបាយ និងសេដ្ឋកិច្ច........................................៣

២.១. រចនាសម្ព័ន្ធ នយោបាយ........................................៣

២.២. រចនាសម្ព័ន្ធរដ្ឋបាល និងសេដ្ឋកិច្ច........................................៤

៣. ស្ថានភាពគ្រឿងញៀន........................................៥

៣.១. ស្ថានភាពគ្រឿងញៀនក្នុងតំបន់ និងលើពិភពលោក........................................៥

៣.២. ស្ថានភាពគ្រឿងញៀនក្នុងប្រទេស........................................៧

៣.៣. ការផលិត និងការដាំដុះគ្រឿងញៀនខុសច្បាប់........................................៧

៣.៤. ការចរាចរគ្រឿងញៀន........................................៨

៣.៥. ការប្រើបំពានគ្រឿងញៀន និងឧក្រិដ្ឋកម្មទាក់ទងគ្រឿងញៀន........................................៩

៤. សកម្មភាពត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា........................................១០

៤.១. រចនាសម្ព័ន្ធចាត់តាំងរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន........................................១០

៤.២. សកម្មភាពត្រួតពិនិត្យគ្រឿងញៀន........................................១០

៤.៣. កិច្ចសហប្រតិបត្តិការរវាង អ.ជ.ប.គ.ញ និងសហគមន៍ផ្តល់ជំនួយ ស្ថាប័នអង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជននានា........................................១១

៤.៤. ការវាយតំលៃលើសកម្មភាពត្រួតពិនិត្យគ្រឿងញៀន លទ្ធផលដែលទទួលបាន ការខ្វះខាត........................................១២

II. **ជំពូកទី២ គោលការណ៍ យុទ្ធសាស្ត្រ និងទិសដៅ**.................................១៤

១. គោលការណ៍.................................................................... ១៤

២. យុទ្ធសាស្ត្រ.................................................................... ១៤

៣. ទិសដៅយូរអង្វែង................................................................ ១៤

៤. ទិសដៅចំពោះមុខ................................................................ ១៤

៤.១. ការពង្រឹងរចនាសម្ព័ន្ធរបស់ អ.ជ.ប.គ.ញ និងស្ថាប័នពាក់ព័ន្ធនានា.................... ១៤

៤.២. ការកាត់បន្ថយតំរូវការគ្រឿងញៀន................................................ ១៥

៤.៣. ការកាត់បន្ថយដំណាំគ្រឿងញៀនខុសច្បាប់.......................................... ១៥

៤.៤. ការត្រួតពិនិត្យ ការផលិត និងការចរាចរគ្រឿងញៀនខុសច្បាប់........................ ១៦

៤.៥. ការងារនីតិកម្ម.................................................................. ១៦

៤.៦. ការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម.................................... ១៧

III. **ជំពូកទី៣ កម្មវិធីសកម្មភាពត្រួតពិនិត្យគ្រឿងញៀន**.................................១៨

១. ពង្រឹងរចនាសម្ព័ន្ធ អ.ជ.ប.គ.ញ និងបណ្តាស្ថាប័នពាក់ព័ន្ធ.................................... ១៨

២. ការកាត់បន្ថយតំរូវការគ្រឿងញៀន..................................................... ១៩

៣. ការកាត់បន្ថយដំណាំគ្រឿងញៀន....................................................... ២១

៤. ការត្រួតពិនិត្យ ការផលិតនិងការចរាចរគ្រឿងញៀនខុសច្បាប់.................................. ២២

៥. ការងារនីតិកម្ម..................................................................... ២៥

៦. ការព្យាបាល ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀន......... ២៦

IV. **ជំពូកទី៤ តំរូវការធនធាន និងហិរញ្ញវត្ថុ**.......................................... ២៩

១. តំរូវការធនធានមនុស្ស .............................................................. ២៩

២. តំរូវការទីតាំង និងសំភារៈផ្សេងៗ .................................................... ២៩

៣. តំរូវការថវិកាសរុប .................................................................. ៣០

៤. បញ្ហាអាទិភាព និងតំរូវការថវិកា ...................................................... ៣០

៥. ផែនការសកម្មភាពលំអិតប្រចាំឆ្នាំ និងថវិកា ........ ៣០

V. **ជំពូកទី៥ ការអនុវត្តន៍គំរោងអាទិភាពនានាក្នុងកិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិ** ........ ៣២

១. គំរោង: AD/CMB/O1/F14 ........ ៣២

២. គំរោង: AD/RAS/99/D91 ........ ៣៣

៣. គំរោង: AD/RAS/01/F34 ........ ៣៤

៤. គំរោង: AD/RAS/00/F73 ........ ៣៥

៥. គំរោង: F97 ការប្រមូលទិន្នន័យ ATS ........ ៣៦

៦. គំរោង: AD/RAS/02/G22 ........ ៣៧

៧. គំរោង: កម្មវិធីលើកកំពស់កិច្ចសហប្រតិបត្តិការបច្ចេកទេសក្នុងតំបន់ ........ ៣៧

៨. គំរោង: CMB/O3/006/A/RC/34 ........ ៣៨

៩. គំរោង កសាងសមត្ថភាពជាតិសំរាប់ធ្វើការវាយតំលៃរហ័សអំពីបញ្ហាគ្រឿងញៀន និងអន្តរាគមន៍ ចំពោះក្រុមប្រជាជនគោលដៅ ........ ៣៩

VI. **ជំពូកទី៦ ការតាមដាន និងវាយតំលៃ** ........ ៤០

១. យន្តការ និងបែបបទសំរាប់តាមដាន និងវាយតំលៃ ........ ៤០

២. កាលវិភាគសំរាប់ការវាយតំលៃ ........ ៤០

៣. ការធ្វើវិសោធនកម្មផែនការជាតិ ........ ៤០

VII. **តារាងឧបសម្ព័ន្ធ** ........

VIII. **ពាក្យសង្ខេប និងអត្ថន័យពាក្យសង្ខេប** ........ a-b

IX. **តារាងពន្យល់ពាក្យបច្ចេកទេស** ........ 1-3

# សេចក្តីផ្តើម

បណ្តាប្រទេសជាច្រើនលើពិភពលោក ទាំងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសជឿនលឿនសុទ្ធតែបានទទួលរងនូវការជ្រៀតចូលនៃគ្រឿងញៀន ។

គ្រឿងញៀនជាសារធាតុដែលមានឥទ្ធិពលលើសារពាង្គកាយនិងប្រព័ន្ធសរសៃប្រសាទ ។ ប្រភេទគ្រឿងញៀនខ្លះត្រូវបានគេស្គាល់និងប្រើប្រាស់ជាយូរលង់មកហើយ ។

គ្រឿងញៀនគេអាចបែងចែកជា២ប្រភេទគឺ : **គ្រឿងញៀនធម្មជាតិ** និង **គ្រឿងញៀនសំយោគ** ។ គ្រឿងញៀនធម្មជាតិមានដូចជា កញ្ឆា អាភៀន កូកាអ៊ីន ... ដែលជារុក្ខជាតិត្រូវបានគេដាំតាំងពីយូរយារណាស់មកហើយ ។ ក្រោយមកទៀតដោយវិទ្យាសាស្ត្រមានការរីកចំរើន និងដើម្បីឆ្លើយតបទៅនឹងតំរូវការរបស់អ្នកប្រើប្រាស់ គេបានផលិតនូវគ្រឿងញៀនមួយប្រភេទទៀតដែលហៅថា **គ្រឿងញៀនសំយោគ** ដូចជា អំហ្វេតាមីន មេតំហ្វេតាមីន អិចស្តាស៊ី..... វាជាគ្រឿងញៀនគីមីដែលបានមកពីការយកសារធាតុគីមីផ្សំជាច្រើនមុខទៅធ្វើសំយោគ ។

ដោយសារវិធានការត្រួតពិនិត្យសារធាតុគីមីផ្សំពុំបានហ្មត់ចត់ បណ្តាលឱ្យមានការបង្វែរសារធាតុគីមីទាំងនោះទៅលើទីផ្សារខុសច្បាប់ធ្វើឱ្យមានកំណើននៃការផលិតដោយលួចលាក់នូវគ្រឿងញៀន ATS ។

ទំហំនិងការកើនឡើងនៃការផលិតគ្រឿងញៀន និងសារធាតុមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទខុសច្បាប់ បង្កើតបានជាបញ្ហាដ៏ធ្ងន់ធ្ងរគំរាមកំហែងចំពោះសុខមាលភាពរបស់មនុស្ស ហើយបានជះឥទ្ធិពលអាក្រក់ទៅលើគ្រឹះសេដ្ឋកិច្ច វប្បធម៌ និងនយោបាយរបស់ប្រទេសនីមួយៗ ។

ភាពរីករាលដាលនៃការចរាចរគ្រឿងញៀនខុសច្បាប់ធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សង្គមជាពិសេសបំផុតនោះ គឺកុមារនិងយុវជននៅក្នុងតំបន់ជាច្រើននៃពិភពលោកត្រូវបានគេធ្វើអាជីវកម្មក្នុងឋានៈជាអ្នកប្រើប្រាស់គ្រឿងញៀន ។ ទាំងនោះគឺជាគ្រោះថ្នាក់មួយដ៏ធ្ងន់ធ្ងរដែលគេមិនអាចវាស់ស្ទង់បាន ។

ការចរាចរគ្រឿងញៀនខុសច្បាប់គឺជាសកម្មភាពឧក្រិដ្ឋមានលក្ខណៈជាអន្តរជាតិ និងមានចំណងទាក់ទងប្រទាក់ក្រឡាគ្នា ក្នុងគោលបំណងបំផ្លាញគ្រឹះសេដ្ឋកិច្ច និងគំរាមកំហែងដល់ស្ថេរភាព អធិបតេយ្យភាពនៃបណ្តាប្រទេសនានាលើពិភពលោក ។

គ្រឿងញៀនគឺជាប្រភពនៃបទល្មើសច្រើនរូបភាព ដែលឈានទៅបង្កើតនូវសេដ្ឋកិច្ចសំងាត់មួយសូម្បីតែស្ថាប័នអនុវត្តច្បាប់នៃបណ្តាប្រទេសជឿនលឿនក៏ពិបាកក្នុងការស្រាវជ្រាវ និងស៊ើបអង្កេតផងដែរ ។

ជំនួញខុសច្បាប់នៃគ្រឿងញៀននឹងត្រូវបានក្លាយទៅជាសោកនាដកម្មមួយដែលធ្វើឱ្យពិភពលោកទាំងមូលមានក្តីកង្វល់ និងបង្កើតបានជាបញ្ហាដ៏ធ្ងន់ធ្ងរមួយក្នុងចំណោមបញ្ហាធ្ងន់ធ្ងរទាំងឡាយដែលពិភពលោកត្រូវប្រឈមមុខនាពេលបច្ចុប្បន្ន ។ នៅអាស៊ីអគ្នេយ៍ក៏មានសភាពដូចតំបន់មួយចំនួនលើពិភពលោកដែរដោយហេតុថា មានការផលិតអាភៀននៅ **តំបន់ត្រីកោណមាស** ដែលជាតំបន់ព្រំដែនរវាងប្រទេស ភូមា ថៃ និងឡាវ ។ អាស្រ័យដោយព្រះរាជាណាចក្រកម្ពុជាមានព្រំប្រទល់ជាប់នឹងប្រទេសថៃ និងប្រទេសឡាវ នោះកម្ពុជាក៏ជៀសមិនផុតពីការឆ្លងកាត់ ការប្រើប្រាស់ និងជាកន្លែងសំអាតប្រាក់ដែលបានមកពីជំនួញគ្រឿងញៀនខុសច្បាប់នោះដែរ ។

អ្នកញៀនគ្រឿងញៀនគឺជាអ្នករងគ្រោះបណ្តាលមកពីមហិច្ឆិតារបស់អ្នកជួញដូរគ្រឿងញៀន ។ ពួកគេទទួលវាសនាអាក្រក់មិនត្រឹមតែបុគ្គលខ្លួនឯងប៉ុណ្ណោះទេគឺត្រូវធ្លាក់ក្នុងបន្ទុកក្រុមគ្រួសារទាំងមូលព្រមទាំងទៅដល់សង្គមជាតិទៀតផង ។ អ្នកញៀនគ្រឿងញៀនគឺពិតជាអ្នកជំងឺដែលត្រូវតែមានសិទ្ធិទទួលនូវការជួយឧបត្ថម្ភ និងសិទ្ធិទទួលភ័ព្វសំណាងជាលើកទីពីរនៅក្នុងជីវិតរបស់គេក្រោយពីបានស្តារនីតិសម្បទាហើយ ។

ការបង្ក្រាបជំនួញគ្រឿងញៀនខុសច្បាប់ គឺជាបញ្ហាអាទិភាពមួយដែលបានកំណត់នៅក្នុងបណ្តាអង្គភាពអនុវត្តច្បាប់ ។ មន្ត្រីអនុវត្តច្បាប់ត្រូវតែមានជំនាញបច្ចេកទេស យល់ដឹងអំពីអត្តសញ្ញាណគ្រឿងញៀន និងច្បាប់គ្រឿងញៀនព្រមទាំងមានវិធីសាស្ត្រគ្រប់គ្រាន់ក្នុងការប្រមូលពត៌មាន តាមដាន ស៊ើបអង្កេតឃ្លាំមើលលើរាល់សកម្មភាពពាក់ព័ន្ធគ្រឿងញៀន នោះទើបអាចដំណើរការមានប្រសិទ្ធិភាពខ្ពស់ ។

ដោយឡែកប្រទេសកម្ពុជាកំពុងរងនូវការគំរាមកំហែងអំពីគ្រឿងញៀនលើគ្រប់រូបភាពដូចជា ការចរាចរ ការស្តុកទុក ការផលិត ការឆ្លងកាត់ និងការប្រើបំពានគ្រឿងញៀន ដែលទាមទារត្រូវមានវិធានការដើម្បីទប់ស្កាត់នូវរាល់សកម្មភាពគ្រោះថ្នាក់ទាំងនេះយ៉ាងម៉ឺងម៉ាត់បំផុត ។

អាស្រ័យដោយគ្រឿងញៀនមានសភាពស្មុគ្រស្មាញ និងប្រកបដោយគ្រោះថ្នាក់ចំពោះសង្គមជាតិទាំងមូលនោះ ទើបផែនការជាតិនេះត្រូវបានរៀបរៀងឡើង ។

# ផែនការជាតិ ៥ឆ្នាំ
# ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
# (២០០៥-២០១០)

ផែនការជាតិនេះបែងចែកជា ៦ជំពូក:

ជំពូក **I** : ស្ថានភាពទូទៅ

ជំពូក **II** : គោលការណ៍ យុទ្ធសាស្ត្រ និង ទិសដៅ

ជំពូក **III** : កម្មវិធីសកម្មភាពត្រួតពិនិត្យគ្រឿងញៀន

ជំពូក **IV** : តំរូវការធនធាន និងហិរញ្ញវត្ថុ

ជំពូក **V** : ការអនុវត្តន៍គំរោងអាទិភាពនានាក្នុងកិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិ

ជំពូក **VI** : ការតាមដាន និងការវាយតំលៃ

# ជំពូក ១

# ស្ថានភាពទូទៅ

# ជំពូក I

## ស្ថានភាពទូទៅ

## ១. ស្ថានភាពភូមិសាស្ត្រ និងប្រជាជន

### ១.១. ទីតាំងភូមិសាស្ត្រ[១]

ព្រះរាជាណាចក្រកម្ពុជា មានទីតាំងស្ថិតនៅអាស៊ីភាគអាគ្នេយ៍ ខាងត្បូងឧបទ្វីបឥណ្ឌូចិនមានផ្ទៃដី ១៨១.០៣៥គ.ម[២] ស្ថិតនៅចន្លោះខ្សែស្របទី១០និង១៥ នៃរយៈទទឹងខាងជើង និងចន្លោះខ្សែបណ្តោយទី១០២និង១០៨ នៃរយៈបណ្តោយខាងកើត។

#### ១.១.ក ព្រំប្រទល់ប្រទេស

ព្រះរាជាណាចក្រកម្ពុជាមានព្រំប្រទល់ប្រវែង ២.៦០០គ.ម គឺព្រំប្រទល់ដីគោក ៥/៦ និងឆ្នេរសមុទ្រ១/៦ដែលមានព្រំប្រទល់ខាងជើងជាប់និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ខាងកើតនិងខាងត្បូងជាប់ជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ខាងលិចជាប់ជាមួយព្រះរាជាណាចក្រថៃ និងឈូងសមុទ្រថៃដែលមានឆ្នេរប្រវែង ៤៤០ គ.ម និងមានជំរៅមធ្យម។

#### ១.១.ខ សណ្ឋានដី :

ព្រះរាជាណាចក្រកម្ពុជា មានផ្ទៃដីរាងជាបាតខ្ទះ វាលទំនាបកណ្តាលពទ្ធ័ជុំវិញទៅដោយភ្នំខ្ពង់រាប និងតំបន់សមុទ្រនៅទិសនិរតី ដោយបែងចែកជាបួនផ្នែកធំៗ :

- តំបន់វាលរាប : ស្ថិតនៅវាលទំនាបកណ្តាលដែលមានដង់ស៊ីតេប្រជាជន ២៣៥នាក់/គ.ម[២] រួមមាន រាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ចាម ស្វាយរៀង ព្រៃវែង និងតាកែវ។

- តំបន់បឹងទន្លេសាប : រួមមានខេត្តបាត់ដំបង កំពង់ធំ សៀមរាប បន្ទាយមានជ័យ ពោធិសាត់ កំពង់ឆ្នាំង ដែលមានដង់ស៊ីតេប្រជាជន ៥៧នាក់/គ.ម[២]។

- តំបន់ឆ្នេរសមុទ្រ : រួមមាន ក្រុងព្រះសីហនុ ក្រុងកែប ខេត្តកំពត និងកោះកុង ដែលមានដង់ស៊ីតេប្រជាជន ៤៩ នាក់/គ.ម[២] ស្ថិតនៅប៉ែកនិរតីនៃប្រទេស។

- តំបន់ខ្ពង់រាប និងភ្នំ : មានប្រជាជនរស់នៅតិចតួចដែលមានដង់ស៊ីតេ ១៧នាក់/គ.ម[២]។ តំបន់នេះ រួមមានក្រុងប៉ៃលិន ខេត្តកំពង់ស្ពឺ ឧត្តរមានជ័យ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគីរី និងមណ្ឌលគីរី។

### ១.២. អាកាសធាតុ[២]

[1-2] សៀវភៅភូមិសាស្ត្រប្រទេសកម្ពុជា

ព្រះរាជាណាចក្រកម្ពុជាស្ថិតក្នុងតំបន់ត្រូពិកក្តៅហើយសើមនិងស្ថិតក្នុងតំបន់អាស៊ីមូសុងសំបូរដោយទឹកភ្លៀង និងមានលក្ខណៈអំណោយផលដល់ការលូតលាស់នៃរុក្ខជាតិនិងដំណាំគ្រប់ប្រភេទ មានសីតុណ្ហភាពមធ្យម អតិបរមាពីចន្លោះ ២៧.៥ ដល់ ២៩.៥ អង្សាសេ និងសីតុណ្ហភាពមធ្យមអប្បបរមាចន្លោះពី ២៤ ដល់ ២៦.៥អង្សាសេ អាកាសធាតុមានការប្រែប្រួលបន្តិចបន្តួចតាមតំបន់និងតាមឆ្នាំដូចជានៅតំបន់ភ្នំនិងខ្ពង់រាប ។

### ១.៣. ស្ថានភាពប្រជាជន សាសនា ទំនៀមទំលាប់ ប្រពៃណី[៣]

ផ្អែកតាមស្ថិតិដែលបានមកពីការជំរឿនប្រជាពលរដ្ឋនៅឆ្នាំ១៩៩៨ នៃវិទ្យាស្ថានជាតិស្ថិតិ(NIS) របស់ក្រសួងផែនការបានបង្ហាញអោយដឹងថា ប្រទេសកម្ពុជាមានពលរដ្ឋសរុបចំនួន ១១,៤៤លាននាក់ ជាមួយនឹងការប៉ាន់ប្រមាណនូវកំណើនប្រជាជនក្នុងអត្រា ២,៤%ក្នុងមួយឆ្នាំ។ រហូតមកដល់បច្ចុប្បន្ននេះ តួលេខពិតប្រាកដអាចកើនឡើងដល់ ១៣លាននាក់ ។

ព្រះរាជាណាចក្រកម្ពុជា ប្រកាន់យកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។ ក្រៅពីនេះក៏មានសាសនាផ្សេងៗទៀតផងដែរដូចជា សាសនាឥស្លាម គ្រឹស្ទសាសនា ។ល។ ប្រជាពលរដ្ឋកម្ពុជាមានទំលាប់រស់នៅស្លូតបូត រាក់ទាក់ ប្រកាន់យករបរកសិកម្មជាមូលដ្ឋាន ។ ប្រទេសកម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេសដែលក្រីក្រលើពិភពលោក ចំណែកឯតំរូវការស្បៀង និងតំរូវការ ការងារកំពុងតែកើនឡើងជាលំដាប់ ។

### ១.៤. រចនាសម្ព័ន្ធសង្គម ( ការអប់រំ សុខាភិបាល និងសេវាសង្គមផ្សេងៗ )

ព្រះរាជាណាចក្រកម្ពុជាបានឆ្លងកាត់សង្គ្រាមរ៉ាំរ៉ៃដ៏យូរលង់ និងរបបប្រល័យពូជសាសន៍( ប៉ុល ពត) ដែលបានបំផ្លាញនូវហេដ្ឋារចនាសម្ព័ន្ធសង្គម និងធនធានមនុស្សស្ទើរតែទាំងស្រុង ។ រាជរដ្ឋាភិបាលបាននឹងកំពុងខិតខំស្តារឡើងវិញលើគ្រប់វិស័យដូចជា វិស័យអប់រំ សុខាភិបាល ។ល ។ ដើម្បីលើកកំពស់ការយល់ដឹងសុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសនៅតាមជនបទ ។

ទោះបីមានការខិតខំប្រឹងប្រែងពីសំណាក់រាជរដ្ឋាភិបាល និងសង្គមស៊ីវិលដទៃទៀតក្តី ប្រជាពលរដ្ឋភាគច្រើនដែលរស់នៅទាំងក្នុងទីក្រុង និងជនបទនៅតែពុំទាន់ទទួលបាននូវការយល់ដឹងសមស្របទៅនឹងការវិវត្តន៍នៃសង្គមនៅឡើយ ។

## ២. របបនយោបាយ និងសេដ្ឋកិច្ច

### ២.១. រចនាសម្ព័ន្ធ នយោបាយ[៤]

---

[3] សៀវភៅជំរឿនទូទៅ ប្រជារាស្ត្រកម្ពុជាឆ្នាំ ១៩៩៨ ( បោះពុម្ពឆ្នាំ ១៩៩៩-២០០០ របស់វិទ្យាស្ថានស្ថិតិ នៃក្រសួងផែនការ)

[4] សៀវភៅរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានាឆ្នាំ១៩៩៣ បានប្រកាន់យករបបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ ដែលមានព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ព្រះអង្គគ្រងរាជ្យ ប៉ុន្តែមិនកាន់អំណាចឡើយ។ ប្រទេសកម្ពុជាជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ។ រដ្ឋធម្មនុញ្ញបានបែងចែកអំណាចជាបីដាច់ដោយឡែកពីគ្នា គឺអំណាចនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ។

<u>អំណាចនីតិប្បញ្ញត្តិ</u>: រួមមានស្ថាប័ន ព្រឹទ្ធសភា និងរដ្ឋសភា។ រដ្ឋសភាកើតឡើងដោយការបោះឆ្នោតជាសកលក្នុងកំឡុងពេល៥ឆ្នាំម្តង។ ចំណែកព្រឹទ្ធសភាមានអណត្តិ៦ឆ្នាំហើយត្រូវមានចំនួនស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភា កើតឡើងដោយការចាត់តាំងខ្លះ និងដោយការបោះឆ្នោតអសកលខ្លះ។

<u>អំណាចនីតិប្រតិបត្តិ</u> : គឺជាស្ថាប័នរាជរដ្ឋាភិបាល ដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ ជាសមាជិក។

<u>អំណាចតុលាការ</u> : ជាស្ថាបន័ឯករាជ្យដែលមានបីថ្នាក់គឺ តុលាការខេត្តក្រុង សាលាឧទ្ធរណ៍ និងតុលាការកំពូល ដើម្បីធានារក្សាការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។

## ២.២. រចនាសម្ព័ន្ធរដ្ឋបាល និង សេដ្ឋកិច្ច [៥]

ព្រះរាជាណាចក្រកម្ពុជាចែកចេញជា ២៤ខេត្ត-ក្រុង ក្នុងនោះរួមមាន ១៨៥ស្រុក-ខ័ណ្ឌ, ១.៦២១ឃុំ-សង្កាត់ និង១៣.៧០៧ភូមិ។ បន្ទាប់ពីសង្គ្រាមត្រូវបានបញ្ចប់ រាជរដ្ឋាភិបាលខិតខំប្រឹងប្រែងពុះពាររាល់ឧបសគ្គ ដើម្បីស្តារឡើងវិញនូវខឿនសេដ្ឋកិច្ចជាតិដែលបានធ្លាក់ចុះក្រោមកំរិតសូន្យ។ ប៉ុន្តែទោះបីមានការខិតខំប្រឹងប្រែងបែបនេះក្តី រហូតមកដល់បច្ចុប្បន្នប្រជាពលរដ្ឋប្រមាណ ៣៦ភាគរយនៅតែស្ថិតនៅក្រោមបន្ទាត់នៃភាពក្រីក្រ។ ប្រាក់ចំណូលរបស់គេស្ថិតក្នុងកំរិតទាបនៅឡើយពោលគឺប្រមាណ ២៥០-២៨០ ដុល្លារក្នុងមួយឆ្នាំសំរាប់មនុស្សម្នាក់។ វបរកសិកម្ម គឺជាប្រភពចំណូលដ៏សំខាន់របស់ប្រជាពលរដ្ឋទូទាំងប្រទេស។ វិស័យទេសចរណ៍សព្វថ្ងៃកំពុងមានភាពរីកចំរើនជាលំដាប់។ វិស័យឧស្សាហកម្មធុនធ្ងន់ពុំទាន់បានដំណើរការនៅឡើយ។ ចំណូលជាតិបច្ចុប្បន្នភាគច្រើនបានមកពីវិស័យពន្ធដារ។ ប្រជាពលរដ្ឋបានប្រមូលផ្តុំពីជនបទមកទីក្រុង ដើម្បីបំរើឱ្យវិស័យក្រុមហ៊ុនកាត់ដេរដែលសព្វថ្ងៃនេះអាចជួយជីវភាពប្រជាពលរដ្ឋបានល្អបង្គួរ ដោយឡែកប្រជាពលរដ្ឋដែលរស់នៅតាមជនបទព្រៃភ្នំដាច់ស្រយាលនៅជួបការលំបាកយ៉ាងខ្លាំងចំពោះជីវភាពរស់នៅប្រចាំថ្ងៃ។ រាជរដ្ឋាភិបាលកំពុងតែយកចិត្តទុកដាក់អនុវត្តគោលនយោបាយអភិវឌ្ឍន៍លើគ្រប់វិស័យដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

[5] សង្ខេបអត្ថន័យ ដកស្រង់ចេញពីសៀវភៅផែនការ អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ៥ ឆ្នាំលើកទី ២ (២០០១-២០០៥)

# ៣. ស្ថានភាពគ្រឿងញៀន

## ៣.១. ស្ថានភាពគ្រឿងញៀនក្នុងតំបន់ និង នៅលើពិភពលោក[6]

### ៣.១.ក. អាភៀន និង ហេរ៉ូអ៊ីន

អាភៀន និងហេរ៉ូអ៊ីនខុសច្បាប់នៅលើពិភពលោកដែលត្រូវបានផលិតច្រើនបំផុតគឺមកពីតំបន់អឌ្ឍច័ន្ទមាស( អាហ្វហ្គានីស្ថាន...)ដែលស្ថិតក្នុងលំដាប់ថ្នាក់លេខ១ មានផលិតផលស្មើនឹង៣/៤នៃផលិតផលលើពិភពលោក និងមួយចំនួនទៀតត្រូវបានផលិតនៅក្នុងតំបន់ត្រីកោណមាស និងនៅទ្វីបអាមេរិកខាងត្បូង។ ចាប់តាំងពីឆ្នាំ២០០០ ដល់ឆ្នាំ២០០១ ការផលិតអាភៀននៅលើពិភពលោកបានធ្លាក់ចុះចំនួន៦៥% ( ផលិតផលត្រូវបានគេប៉ាន់ស្មានថាមានចំនួន ៤.៧០០តោនក្នុងឆ្នាំ២០០០និង ១.៦០០តោនក្នុងឆ្នាំ២០០១) ។ ចន្លោះឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០២ ការដាំអាភៀននៅតំបន់ត្រីកោណមាសបានធ្លាក់ចុះ ៤០% ។

ការផលិតហេរ៉ូអ៊ីនខុសច្បាប់ក្នុងឆ្នាំ២០០២ មានចំនួនសរុបប្រហែល ៤៥០តោន។ UNODC បានប៉ាន់ស្មានថា អ្នកប្រើប្រាស់អាភៀន និងហេរ៉ូអ៊ីនទូទាំងពិភពលោកប្រមាណ១៥លាននាក់ជាមួយគ្នានោះដែរក៏មានការប្រើប្រាស់ហេរ៉ូអ៊ីន ដោយប្រើម្ជុលចាក់ចូលសរសៃឈាមដែលអាចបណ្តាលអោយមានការឆ្លងរីករាលដាលនៃមេរោគហ៊ីវ/អេដស៍ ក្នុងអត្រាមួយដែលស្ថិតក្នុងភាពអាសន្ន។ ទីផ្សារ ដ៏ធំនៃអាភៀន និងហេរ៉ូអ៊ីនខុសច្បាប់ គឺនៅក្នុងតំបន់ អាស៊ីកណ្តាល និងអឺរ៉ុប។

### ៣.១.ខ. កូកាអ៊ីន

កូកាអ៊ីន គឺជាគ្រឿងញៀនដ៏សំខាន់ស្ថិតក្នុងចំណាត់ថ្នាក់លេខពីរលើពិភពលោកដែលត្រូវបានគេប្រើប្រាស់បំពាន ជាពិសេសនៅទ្វីបអាមេរិក។ តួលេខសរុបនៃការផលិតកូកាអ៊ីនមានចំនួនប្រមាណ ៨០០តោននៅឆ្នាំ២០០២។ ចំនួនអ្នកប្រើប្រាស់កូកាអ៊ីនមានប្រមាណ ១៤លាននាក់ដែលក្នុងនោះ គេកត់សំគាល់ឃើញមានការកើនឡើងនូវការប្រើគ្រឿងញៀននេះនៅអាមេរិកខាងត្បូង។ កូឡុំប៊ីគឺជាប្រភពដ៏ធំបំផុតនៃការផលិតកូកាអ៊ីនលើពិភពលោកបន្ទាប់មកគឺ ប៉េរូ និងបូលីវី។ អ្នកជួញដូរកូកាអ៊ីនបាននឹងកំពុងស្វែងរកទីផ្សារថ្មីនៅអឺរ៉ុប។

### ៣.១.គ. កញ្ឆា

គឺជាប្រភេទគ្រឿងញៀនមួយត្រូវបានគេផលិត ចរាចរ និងប្រើប្រាស់ទូលំទូលាយពាសពេញពិភពលោក។ ការធ្វើស្ថិតិនិងប្រព័ន្ធត្រួតពិនិត្យលើការដាំដុះពុំអាចធ្វើការវាយតំលៃបានពិតប្រាកដ

[6] សង្ខេបចេញពីសៀវភៅ Global Illicit Drug Trends 2003

អំពីទីតាំង វិសាលភាព ការវិវត្តន៍នៃការដាំនិងការផលិតនៅលើពិភពលោកបានទេ ។ ដូច្នេះមានតែតាមរយៈលទ្ធផលនៃការចាប់ផលិតផលកញ្ឆាខុសច្បាប់ដែលជាពន្លឺឆ្លុះបញ្ចាំងពីប្រភពនៃបណ្តាប្រទេសដែលដាំកញ្ឆាលើពិភពលោក ។ ប៉ុន្តែបច្ចេកវិទ្យាថ្មីសំរាប់ធ្វើការអង្កេតដ៏មានប្រសិទ្ធិភាពទៅលើដំណាំកញ្ឆាត្រូវបានដំណើរការហើយ ។

ប៉ុន្មានឆ្នាំថ្មីៗនេះ ដំណាំកញ្ឆាបានថយចុះ ទាំងនេះបានបង្ហាញអំពីកិច្ចខិតខំប្រឹងប្រែងក្នុងការលប់បំបាត់ដំណាំកញ្ឆារបស់ស្ថាប័នអនុវត្តច្បាប់ ។ តួលេខចាប់កញ្ឆានាឆ្នាំ២០០០មានចំនួន ២៣.៩០០តោន និងឆ្នាំ២០០១មានចំនួន ១៨.៥០០តោន ។

### ៣.១.ឃ. ATS: "Amphetamine-Type-Stimulants" **អំហ្វេតាមីនប្រភេទលើកកំលាំង**

អាស៊ី គឺជាតំបន់សំខាន់មួយក្នុងការផលិតមេតំហ្វេតាមីន (Methamphetamine) ក្នុងនោះគេកត់សំគាល់មានប្រទេសចំនួនបីជាសំខាន់គឺ សាធារណរដ្ឋប្រជាមានិតចិន ថៃ និងភូមា ។ ការផលិតមេតំហ្វេតាមីនបានកើនឡើងយ៉ាងខ្លាំងនាចុងទសវត្សឆ្នាំ៩០ ។ លទ្ធផលនៃការចាប់រឹបអូស មេតំហ្វេ-តាមីន(៤១តោនក្នុងឆ្នាំ២០០០ និង២៦តោនក្នុងឆ្នាំ២០០១) បានចង្អុលបង្ហាញផងដែរអំពីវត្តមាននៃសារធាតុគីមីផ្សំដែលមានទ្រង់ទ្រាយធំចាំបាច់ក្នុងការផលិតការប្រើប្រាស់នៅក្នុងតំបន់ និងការចរាចរដ៏គំហុកឆ្លងកាត់តំបន់ ។

ថ្មីៗនេះ ដោយមានយុទ្ធនាការបង្ក្រាបយ៉ាងធំទៅលើ ការផលិត ការចរាចរ និងការប្រើគ្រឿងញៀនខុសច្បាប់នៅប្រទេសថៃ (ស្មើនឹង២៩% នៃការចាប់មេតំហ្វេតាមីន នៅអាស៊ីខាងកើតនិងអាស៊ីអាគ្នេយ៍) បានធ្វើឱ្យបណ្តាញជួញដូរគ្រឿងញៀនស្វែងរកកន្លែងផលិតជំនួសនៅក្នុងបណ្តាប្រទេសជិតខាងក្នុងតំបន់ ជាពិសេសប្រទេសដែលប្រព័ន្ធច្បាប់នៅទន់ខ្សោយ ។ ក្រុមឧក្រិដ្ឋជនដែលផលិត និងចរាចរហេរ៉ូអ៊ីនខុសច្បាប់ក៏ពាក់ព័ន្ធជាមួយការផលិត និងការចរាចរមេតំហ្វេតាមីនផងដែរ ។ តាមរយៈការបង្ក្រាបបានរកឃើញទីតាំងលួចលាក់ផលិតមេតំហ្វេតាមីនជាទ្រង់ទ្រាយតូចនៅបណ្តាប្រទេសផ្សេងៗក្នុងតំបន់ ។

ការផលិតអំហ្វេតាមីន(Amphetamine) ភាគច្រើននៅទ្វីបអឺរ៉ុប អាមេរិក និងអូសេអានី ។ ដោយឡែកនៅអូស្ត្រាលី ការផលិតស្មើនឹង២០%នៃផលិតផលអំហ្វេតាមីន ដែលចាប់បានក្នុងអំឡុងឆ្នាំ១៩៨៩-១៩៩៩ ។ នៅអាស៊ី ក៏មានរបាយការណ៍អំពីការចាប់អាស៊ីដហ្វេនីលអាសេទិច(Phenyl-Acetic) ដែលអាចយកទៅប្រើប្រាស់ក្នុងការផលិតអំហ្វេតាមីន និងមេតំហ្វេតាមីនផងដែរ ។

អ៊ិកស្តាស៊ី(Ecstasy) ក៏ត្រូវបានគេរាយការណ៍ថាមានការផលិតនៅ អឺរ៉ុប អាមេរិកខាងជើង និងអូស្ត្រាលី ។ ប៉ុន្មានឆ្នាំថ្មីៗនេះ ការចរាចរបានកើនឡើងជាពិសេសនៅទ្វីបអាមេរិក

អាស៊ីអាគ្នេយ៍ អាហ្វ្រិកខាងត្បូង និងមជ្ឈឹមបូព៌ា។ រីឯសារធាតុគីមីផ្សំរបស់អ៊ិកស្តាស៊ី ត្រូវបានគេនាំមកពីអឺរ៉ុប អាមេរិកខាងជើង និងអាស៊ីក្នុងអំឡុងប៉ុន្មានឆ្នាំថ្មីៗនេះ។

## ៣.២. ស្ថានភាពគ្រឿងញៀនក្នុងប្រទេស[7]

ប្រទេសកម្ពុជា ជាប្រទេសដែលទទួលរងនូវការហូរចូលនៃថ្នាំញៀនខុសច្បាប់គួរអោយព្រួយបារម្ភ ដោយសារ កម្ពុជាជាប្រទេសដែលមានប្រព័ន្ធច្បាប់មិនទាន់មានភាពរឹងមាំ ធនធានមនុស្សនៅមានកំរិតទាប និងភាពក្រីក្រជាទូទៅរបស់ប្រជាពលរដ្ឋ។ ទីតាំងភូមិសាស្ត្រកម្ពុជាស្ថិតនៅជិតតំបន់ត្រីកោណមាសដែលជាចំណែកមួយធ្វើឱ្យកម្ពុជាក្លាយទៅជាតំបន់ ចរាចរ ឆ្លងកាត់ ជួញដូរ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់គួរឱ្យកត់សំគាល់។

## ៣.៣. ការផលិត និងការដាំដុះគ្រឿងញៀនខុសច្បាប់

### ៣.៣.ក. កញ្ឆា

កន្លងមក កញ្ឆាត្រូវបានលួចដាំនៅបណ្តាខេត្តតាមដងទន្លេមេគង្គ តាមតំបន់ព្រៃភ្នំដាច់ស្រយាល និងតាមព្រំដែនដូចជា ក្រុងព្រះសីហនុ ខេត្តកោះកុង បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ចាម ក្រចេះ កំពត កណ្តាល តាកែវ និងកំពង់ស្ពឺ ។ល។

បន្ទាប់ពីមានវិធានការណ៍យ៉ាងតឹងរឹងពីរាជរដ្ឋាភិបាល ជាពិសេសបន្ទាប់ពីសម្តេចនាយករដ្ឋមន្ត្រី និងឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនដឹកនាំយុទ្ធនាការបំផ្លាញដំណាំកញ្ឆាក្នុងទ្រង់ទ្រាយធំនៅខេត្តកំពត និងនៅក្នុងខេត្តកំពង់ចាមនាឆ្នាំ២០០១(សរុបប្រមាណជាង៦០ហិកតា) យើងពិនិត្យឃើញសកម្មភាពដាំដុះដំណាំកញ្ឆាមានការថយចុះជាអតិបរមា។

### ៣.៣.ខ. គ្រឿងញៀនសំយោគ

មានសញ្ញាជាច្រើនដែលធ្វើអោយគេសង្ស័យថា ឧក្រិដ្ឋជនអន្តរជាតិមានបំណងបង្វែរសកម្មភាពទៅរកការផលិតថ្នាំញៀនសំយោគក្នុងប្រទេសកម្ពុជា ជាពិសេសមេតំហ្វេតាមីន។ ក្រៅពីរកឃើញម៉ាស៊ីនផលិត ATS ទ្រង់ទ្រាយធំមួយកន្លែងនៅក្នុងខេត្តកោះកុង(១៦/១១/២០០២) ដែលគ្មានសកម្មភាពយូរឆ្នាំមកហើយនោះ មានតែពុម្ពសង្កត់គ្រាប់ថ្នាំដោយដៃអាចចល័តបានចំនួន៧គ្រឿងប៉ុណ្ណោះដែលសមត្ថកិច្ចចាប់បាន។ មានពត៌មានឱ្យដឹងថាក្រុមឧក្រិដ្ឋជនអន្តរជាតិបានប្តូរទីតាំងផលិតប្រមាណជាង ៤០កន្លែងពីតំបន់ព្រំដែន កម្ពុជា-ថៃ ទៅតំបន់ព្រំដែន ថៃ-ឡាវវិញ ប៉ុន្តែក៏មានសញ្ញាសង្ស័យថានៅតែមានការផលិតតាមតំបន់ព្រំដែនកម្ពុជា-ថៃនៅឡើយ។

---

[7] ដកស្រង់ចេញពីរបាយការណ៍ សិក្ខាសាលាជាតិ ០៥-០៦ ឧសភា ២០០៣ និង របាយការណ៍ កិច្ចប្រជុំបូកសរុប លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០០៣ និង ទិសដៅឆ្នាំ ២០០៤ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ៣.៣.គ. ហេរ៉ូអ៊ីន

ក្រុមឧក្រិដ្ឋជនអន្តរជាតិបាននាំហេរ៉ូអ៊ីនឆ្លងកាត់មកកម្ពុជា ជាពិសេសមកពីតំបន់ត្រីកោណមាស រួចនាំចេញទៅ ប្រទេសទី៣ ដូចជា ប្រទេសអូស្ត្រាលី សឹង្ហបុរី តៃវ៉ាន់ ហុងកុង វៀតណាម ... តាមច្រកព្រលានយន្តហោះអន្តរជាតិភ្នំពេញ កំពង់ផែក្រុងព្រះសីហនុ និងតាមច្រកព្រំដែនគោកនានា ។ ជាទូទៅ ប្រទេសកម្ពុជាពុំមានលទ្ធភាពក្នុងការផលិតហេរ៉ូអ៊ីនទេ ។

### ៣.៣.ឃ. សារធាតុគីមីផ្សំ

ព្រះរាជាណាចក្រកម្ពុជាមិនមានផលិតសារធាតុគីមីផ្សំទេ ប៉ុន្តែស្ថាប័នមានសមត្ថកិច្ចបានអនុញ្ញាតឱ្យមានការនាំចូលដោយស្របច្បាប់នូវសារធាតុគីមីផ្សំមួយចំនួនដូចជា អាស៊ីដអាសេទិក-ក្លាស់ស្យាល់ អាស៊ីដក្លរីឌ្រិក អាស៊ីដស៊ុលផួរិក អេទីលអេទែរ អាសេតោន តូលុយអែន ។ល។ និង ។ល ។ក្នុងមួយឆ្នាំៗមានចំនួនរាប់ពាន់តោនដើម្បីបំរើឱ្យវិស័យឧស្សាហកម្ម ។ ជាមួយនឹងបរិមាណនាំចូលដ៏សន្ធឹកសន្ធាប់នេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនមានការព្រួយបារម្ភចំពោះលទ្ធភាពនៃការលួចបង្វែរសារធាតុទាំងនោះទៅទីផ្សារងងឹតដើម្បីផលិតគ្រឿងញៀនខុសច្បាប់ ។

## ៣.៤. ការចរាចរគ្រឿងញៀន

### ៣.៤.ក.ហេរ៉ូអ៊ីន

ការចរាចរហេរ៉ូអ៊ីនត្រូវបានគេចាប់អារម្មណ៍ជាសំខាន់គឺនៅតំបន់ប៉ែកខាងជើង និងខាងកើតនៃប្រទេសកម្ពុជា ជាពិសេសខេត្តស្ទឹងត្រែង ។ គេពុំអាចគណនាបានពីបរិមាណនៃហេរ៉ូហ៊ីនដែលនាំចូលឆ្លងកាត់មកកម្ពុជា តែគេអាចដឹងតាមរយៈការចាប់និងរឹបអូសនៅក្នុងប្រទេស និងតាមបណ្តាប្រទេសផ្សេងៗដូចជា នៅទីក្រុងស៊ីដនីប្រទេសអូស្ត្រាលី ខេត្តតៃនិញប្រទេសវៀតណាម និងហុងកុងប្រទេសចិន ដែលបានរាយការណ៍ថាបានរត់ពន្ធឆ្លងកាត់ប្រទេសកម្ពុជាតាមរូបភាពដាក់បង្កប់ក្នុងកុងទឺន័រទំនិញ តាមរថយន្ត តាមកប៉ាល់ តាមយន្តហោះ និងតាមកញ្ចប់សំបុត្រផ្ញើតាមប្រៃសណីយ៍ ។

### ៣.៤.ខ.គ្រឿងញៀនសំយោគ

ក្នុងកំឡុងឆ្នាំ២០០៣ ទោះបីមានការត្រួតពិនិត្យយ៉ាងម៉ត់ចត់ពីមន្ត្រីអនុវត្តច្បាប់ ខេត្តស្ទឹងត្រែងនៅតែជាចំនុចក្តៅចំពោះការចរាចរមេតំហ្វេតាមីន មកពីតំបន់ត្រីកោណមាសមកក្នុងប្រទេសកម្ពុជាសំរាប់ប្រើប្រាស់ និងនាំចេញទៅក្រៅប្រទេស ។ ផ្អែកតាមតួលេខបង្ក្រាបដោយមន្ត្រីអនុវត្តច្បាប់បានបង្ហាញថាបណ្តាខេត្តភាគពាយ័ព្យជាប់នឹងប្រទេសថៃ និងបណ្តាខេត្តភាគឦសានជាប់ព្រំប្រទល់ប្រទេសឡាវ គឺជាច្រកដ៏សំខាន់នៃការចរាចរមេតំហ្វេតាមីនចូលមកនិងឆ្លងកាត់ប្រទេសកម្ពុជាដែលបរិមាណនៃការលួចនាំចូលនេះមានការកើនឡើងជារៀងរាល់ឆ្នាំ ។

### ៣.៤.គ.កញ្ឆា

ភាគច្រើននៃការលួចដាំដំណាំកញ្ឆានៅកម្ពុជា គឺក្នុងគោលបំណងសំរាប់នាំចេញទៅក្រៅប្រទេសដូចជា ប្រទេសវៀតណាម ប្រទេសចិន ។ល ។ ប៉ុន្តែបច្ចុប្បន្នបរិមាណនៃការដាំដុះមានការថយចុះជាអតិបរមាក្រោយពីយុទ្ធនាការបំផ្លាញកញ្ឆានាឆ្នាំ២០០១មក ។

## ៣.៥. ការប្រើបំពានគ្រឿងញៀន និងឧក្រិដ្ឋកម្មទាក់ទងគ្រឿងញៀន

### ៣.៥.ក. ការប្រើបំពានគ្រឿងញៀន

ស្ថិតិបណ្តោះអាសន្នផ្តល់ដោយខេត្ត-ក្រុងឆ្នាំ២០០៣បានបង្ហាញថា អ្នកប្រើគ្រឿងញៀននៅទូទាំងប្រទេសមានចំនួន ៤.៣៨៧នាក់ ។ ចំនួននេះគ្រាន់តែជាតួលេខជាក់ស្តែងដែលបានរកឃើញប៉ុណ្ណោះ វាអាចនៅមានចំនួនច្រើនទៀតដែលគេរកមិនឃើញ ។ អ្នកជំនាញផ្នែកគ្រឿងញៀនបានអះអាងថាចំនួនពិតប្រាកដនៃអ្នកប្រើគ្រឿងញៀនអាចស្មើនឹងដប់ដងនៃករណីដែលគេបានរាយការណ៍ បានន័យថាស្មើនឹង ៤៣.៨៧០នាក់ ។ ប៉ុន្តែរបាយការណ៍ប្រចាំឆ្នាំ២០០០ នៃអង្គការUNODC បានបញ្ជាក់ថាអាត្រានៃអ្នកប្រើគ្រឿងញៀននៅក្នុងប្រទេសនីមួយៗមានកំរិតស្មើនឹង៣ទៅ៤ភាគរយនៃចំនួនប្រជាជននៅក្នុងប្រទេសនោះ ។ ប្រសិនបើផ្អែកលើអត្រានេះ ប្រទេសកម្ពុជាអាចមានអ្នកប្រើបំពានគ្រឿងញៀនប្រមាណជា៣៦០.០០០ ទៅ៤៨០.០០០នាក់ ។ បើតាមលទ្ធផលនៃការស្ទាបស្ទង់សាកល្បងជាលើកដំបូងលើការប្រើបំពានគ្រឿងញៀននៅទីក្រុងភ្នំពេញ ក្រុងព្រះសីហនុ និងខេត្តបាត់ដំបង ដែលធ្វើឡើងដោយអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សហការជាមួយមជ្ឈមណ្ឌលរបស់អាមេរិកសំរាប់ត្រួតពិនិត្យនិងបង្ការជម្ងឺ (USCDC) និង UNODC ក្នុងចំណោមសិស្ស៣.៥០០នាក់ ដែលរៀននៅថ្នាក់ទី៩ដល់ថ្នាក់ទី១២ បានបង្ហាញថាមានសិស្សម្នាក់ក្នុងចំណោម៥នាក់បានសាកល្បងប្រើសារធាតុញៀន ។ ការប្រើបំពានគ្រឿងញៀនគ្រប់រូបភាពក្នុងនោះរួមមាន ការលេប ជក់ ហឺត ព្រមទាំងការចាក់បញ្ចូលតាមសរសៃឈាមកំពុងរីករាលដាលគួរឱ្យព្រួយបារម្ភ ។

ការប្រើប្រាស់ភាគច្រើនបានកើតឡើងក្នុងចំណោមយុវវ័យក្នុង និងក្រៅប្រព័ន្ធអប់រំ ។ អ្នកទាំងនោះអាចជាក្រុមយុវវ័យដែលឪពុកម្តាយមានជីវភាពធូរធារ ពលករលក់កំលាំងពលកម្ម កម្មកររោងចក្រសហគ្រាស អ្នករកស៊ី ផ្លូវភេទ ស្ត្រីបំរើនៅតាមក្លឹបកំសាន្ត និងសណ្ឋាគារ ។ល ។ បច្ចុប្បន្ននេះការប្រើបំពានគ្រឿងញៀនបានរាលដាលដល់ក្រុមយុវវ័យដែលឪពុកម្តាយមានជីវភាពក្រីក្រ និងក្រុមកុមារអនាថា ។ បញ្ហាដែលយើងកាន់តែព្រួយបារម្ភគឺការប្រើប្រាស់គ្រឿងញៀនតាមរបៀបចាក់បញ្ចូលតាមសរសៃឈាម និងការរួមភេទគ្មានសុវត្ថិភាពក្រោមឥទ្ធិពលនៃគ្រឿងញៀន ដែលជាហេតុជំរុញឱ្យមានការកើនឡើងនៃការចម្លងមេរោគហ៊ីវ/អេដស៍ និងជំងឺថ្មើម ។

### ៣.៥.ខ. បទល្មើសទាក់ទងនឹងគ្រឿងញៀន

តាមការសង្កេតបានបង្ហាញឱ្យឃើញថាការប្រើបំពានគ្រឿងញៀនបានជំរុញឱ្យមានការកើនឡើងនូវបទល្មើសនានាដូចជា អំពើឆក់ប្លន់ ឃាតកម្ម ការចាប់ជំរិត អំពើហឹង្សាក្នុងគ្រួសារ... ហើយនឹងកាន់តែមានចរិតឃោរឃៅជាងមុន ។

### ៣.៥.គ. ការសំអាតប្រាក់

បច្ចុប្បន្នធនាគារជាតិនៃកម្ពុជា ក្រសួងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ កំពុងសហការជាមួយជំនាញការអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) ក្នុងការតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងនឹងការសំអាតប្រាក់កខ្វក់ និងហិរញ្ញបទានភេរវកម្ម ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសំរេច ។

## ៤. សកម្មភាពត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា

### ៤.១. រចនាសម្ព័ន្ធចាត់តាំងរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន[8]

ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៥ បានចែងពីសមាសភាពរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនរួមមាន សហនាយករដ្ឋមន្ត្រីទាំងពីរជាប្រធាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាអនុប្រធាន និងរដ្ឋមន្ត្រីនៃក្រសួង១០ជាសមាជិក (យុត្តិធម៌ មហាផ្ទៃ ទីស្តីការគណៈរដ្ឋមន្ត្រី សុខាភិបាល ការពារជាតិ ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អប់រំយុវជននិងកីឡា សង្គមកិច្ចការងារ បណ្តុះបណ្តាល វិជ្ជាជីវៈនិងយុវនីតិសម្បទា និងធនាគារជាតិនៃកម្ពុជា) ដែលមានអគ្គលេខាធិការដ្ឋានមួយឈ្មោះថា **អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន** ដែលទទួលខុសត្រូវក្នុងការចាត់ឱ្យអនុវត្តគោលនយោបាយ និងធានាការសំរបសំរួលជាអចិន្ត្រៃយ៍នូវវិធានការរបស់រាជរដ្ឋាភិបាល ។

ក្រោយមកទៀតមានព្រះរាជក្រឹត្យមួយថ្មីទៀតលេខ ជស/រកត/០២០០/១០៨ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការផ្ទេរតំណែងប្រធានអាជ្ញាធរជាតិ ពីនាយករដ្ឋមន្ត្រី មកជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃធ្វើជាប្រធានវិញ ។

### ៤.២. សកម្មភាពត្រួតពិនិត្យគ្រឿងញៀន[9]

#### ៤.២.ក. ដំណាំគ្រឿងញៀនកញ្ឆាៈ

- ឆ្នាំ២០០២ លទ្ធផលបំផ្លាញមានចំនួនជិត ១២ហិកតា ។
- ឆ្នាំ២០០៣ លទ្ធផលបំផ្លាញមានចំនួនជាង ៦ហិកតា ។

---

[8] យោងព្រះរាជក្រឹត្យចុះថ្ងៃទី ០៧ កញ្ញា ១៩៩៥ និង ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៨ ចុះថ្ងៃទី ២២ កុម្ភៈ ឆ្នាំ ២០០០

[9] យោងរបាយការណ៍នៃកិច្ចប្រជុំបូកសរុប លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ ២០០៣

**៤.២.ខ. គ្រឿងញៀនសំយោគៈ**

- ឆ្នាំ២០០២ បង្រ្កាបករណី ATS ៧៧ករណីចាប់ជនល្មើស ២២៣នាក់ ដកហូត ATS ១៣៧.៦៦០គ្រាប់ ។
- ឆ្នាំ២០០៣ បង្រ្កាបករណី ATS ១៨៤ករណីចាប់ជនល្មើស ៣៤៩នាក់ ដកហូត ATS ២០៩.៥២៧គ្រាប់ ។

**៤.២.គ. ហេរ៉ូអ៊ីនៈ**

- ឆ្នាំ២០០២ បង្រ្កាបហេរ៉ូអ៊ីនបាន ១ករណី ចាប់ជនល្មើស ១នាក់ ដកហូតហេរ៉ូអ៊ីនចំនួន ១.៩០០ក្រាម ។
- ឆ្នាំ២០០៣ បង្រ្កាបហេរ៉ូអ៊ីនបាន ៦ករណី ចាប់ជនល្មើស ២៤នាក់ ដកហូតហេរ៉ូអ៊ីន ៤៦.២៧៤ ក្រាម ។

**៤.៣. កិច្ចសហប្រតិបត្តិការរវាង អ.ជ.ប.គ.ញ និងសហគមន៍ផ្តល់ជំនួយ ស្ថាប័នអង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជននានា**

រាជរដ្ឋាភិបាលកម្ពុជាកំពុងស្នើសុំសច្ចាប័នពីរដ្ឋសភា ក្នុងការចូលជាសមាជិកអនុសញ្ញាទាំងបីរបស់អង្គការសហប្រជាជាតិពោលគឺអនុសញ្ញាទោលឆ្នាំ១៩៦១ស្តីពីគ្រឿងញៀន អនុសញ្ញាឆ្នាំ១៩៧១ស្តីពីសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និងអនុសញ្ញា១៩៨៨ស្តីពីការប្រឆាំងនឹងការចរាចរគ្រឿងញៀន និងសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទខុសច្បាប់ ។

រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងទ្វេភាគីជាមួយ ប្រទេសថៃ ឡាវ វៀតណាម និងសហព័ន្ធរុស្ស៊ី ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការត្រួតពិនិត្យការចរាចរគ្រឿងញៀន និងសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ សារធាតុគីមីផ្សំខុសច្បាប់ ។

ទន្ទឹមនោះយើងបានចូលជាសមាជិកនៃបណ្តាប្រទេសហត្ថលេខី MOU អនុតំបន់ (កម្ពុជា វៀតណាម ឡាវ ថៃ មីយ៉ាន់ម៉ា ចិន និងUNODC ) និងមានកិច្ចប្រជុំប្រចាំឆ្នាំត្រីភាគី/ទ្វេភាគី កម្ពុជា វៀតណាម ឡាវ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន និងកិច្ចប្រជុំថ្នាក់ខេត្តតាមបណ្តោយព្រំដែនកម្ពុជា ថៃ វៀតណាម ឡាវ ... ។

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ មានដៃគូដ៏សំខាន់គឺ UNODC ។ ក្រៅពីនោះយើងបានធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទជាមួយបណ្តាស្ថានទូតផ្សេងៗ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជននានា ដែលបំរើការងារលើវិស័យគ្រឿងញៀន ។

-ក្រសួងយុត្តិធម៌បានខិតខំបញ្ចប់ការធ្វើសេចក្តីព្រាងវិសោធនកម្មច្បាប់ត្រួតពិនិត្យគ្រឿងញៀនដែលយើងសង្ឃឹមថានឹងក្លាយជាបទបញ្ញត្តិដ៏តឹងរ៉ឹង និងគ្រប់ជ្រុងជ្រោយ ជួយដល់ស្ថាប័នតុលាការ ក្នុងការវិនិច្ឆ័យទោសចំពោះឧក្រិដ្ឋជនគ្រឿងញៀន ។

- ក្រសួងសុខាភិបាល បានរៀបចំអោយមានកន្លែងសំរាប់ផ្តល់ការពិគ្រោះយោបល់ និងផ្តល់ថ្នាំដល់អ្នកញៀនមួយកន្លែងចំណុះឱ្យផ្នែកជំងឺផ្លូវចិត្តនៅក្នុងមន្ទីរពេទ្យព្រះសីហនុ ។ ដោយឡែកមជ្ឈមណ្ឌល

ស្ដារនីតិសម្បទាចោមចៅ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក៏បានទទួលក្មេងអនាថាមួយចំនួនដែលពាក់ពន្ធ័នឹងគ្រឿងញៀនផងដែរ។ ដើម្បីដោះស្រាយបញ្ហានេះអោយមានប្រសិទ្ធិភាព រាជរដ្ឋាភិបាលបានផ្ដល់គោលការណ៍បង្កើតមជ្ឈមណ្ឌលសំរាប់ព្យាបាលអ្នកញៀនមួយកន្លែងនៅទីក្រុងភ្នំពេញ។

- ក្រសួងអប់រំយុវជននិងកីឡាបានបញ្ចូលបញ្ហាគ្រឿងញៀនទៅក្នុងកម្មវិធីសិក្សាគ្រប់កំរិតចាប់តាំងពីថ្នាក់បឋមរហូតដល់ឧត្តមសិក្សា។

- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចុះអនុស្សារណៈនៃការយោគយល់គ្នាជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៏សំដៅទប់ស្កាត់ការរីករាលដាលនៃការចម្លងមេរោគហ៊ីវ/អេដស៍ តាមរយៈការប្រើប្រាស់គ្រឿងញៀនដោយប្រើម្ជុលចាក់បញ្ចូលតាមសរសៃឈាម និងការរួមភេទដែលមិនធានាសុវត្ថិភាពក្រោមឥទ្ធិពលនៃគ្រឿងញៀន។

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបង្កើត "មជ្ឈមណ្ឌលគ្រប់គ្រងពតិមាន" ដើម្បីមានលទ្ធភាពប្រមូល និងវិភាគពតិមានទាំងឡាយពាក់ព័ន្ធនឹងគ្រឿងញៀន។ មជ្ឈមណ្ឌលនេះក៏ត្រូវបានតភ្ជាប់ជាមួយការិយាល័យ UNODC ប្រចាំតំបន់ដើម្បីផ្លាស់ប្ដូរ និងផ្សព្វផ្សាយពតិមានចាំបាច់នានាជាមួយតំបន់តាមរយៈវែបសាយ (Web-Site )។

- សហការជាមួយUNODC ក្នុងការប្រមូលទិន្នន័យអ្នកប្រើបំពានគ្រឿងញៀនដែលជំហានដំបូងយើងបានរៀបចំចាត់តាំងមន្ត្រីទំនាក់ទំនងនៅតាមបណ្ដាខេត្ត-ក្រុងសំខាន់ៗចំនួន៩ គឺក្រុងភ្នំពេញ ក្រុងប៉ៃលិន ក្រុងព្រះសីហនុ ខេត្តកោះកុង បាត់ដំបង បន្ទាយមានជ័យ កំពង់ចាម កណ្ដាល និងសៀមរាប ហើយខាងមុខនេះយើងនឹងឈានទៅធ្វើនៅគ្រប់ខេត្ត-ក្រុងទូទាំងប្រទេស។

- ដោយមានកិច្ចសហការពី UNODC អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបង្កើតការិយាល័យបណ្ដុះបណ្ដាលមន្ត្រីអនុវត្តច្បាប់ដោយយកកុំព្យូទ័រជាមូលដ្ឋាន (CBT )បានចំនួន៥កន្លែងនៅអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅក្រុងព្រះសីហនុ ខេត្តបាត់ដំបង ខេត្តសៀមរាប និងទីចាត់ការគយនិងរដ្ឋាករ។ បន្ថែមលើនេះយើងបានបង្កើតការិយាល័យទំនាក់ទំនងព្រំដែន (BLO ) នៅច្រកទ្វារព្រំដែនអន្តរជាតិសំខាន់ៗចំនួន៦ គឺច្រកចាំយាមក្នុងខេត្តកោះកុង ច្រកប៉ោយប៉ែតក្នុងខេត្តបន្ទាយមានជ័យ ច្រកដូងក្រឡក្នុងខេត្តស្ទឹងត្រែង ច្រកបាវិតក្នុងខេត្តស្វាយរៀង ច្រកទ្វារក្អមសំណខេត្តកណ្ដាល និងច្រកទ្វារទ្វេភាគីជ្រៃធំខេត្តព្រៃវែង។

## ៤.៤. ការវាយតំលៃលើសកម្មភាពត្រួតពិនិត្យគ្រឿងញៀនលទ្ធផលដែលទទួលបាន និងការខ្វះខាត

អនុវត្តតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល អាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុង រដ្ឋអំណាចមូលដ្ឋានគ្រប់

លំដាប់ថ្នាក់ និងស្ថាប័នពាក់ព័ន្ធនានាបានខិតខំបំពេញនូវភារកិច្ចជំនាញរបស់ខ្លួនក្នុងការបង្ក្រាបករណីផលិតនិងចរាចរគ្រឿងញៀនទទួលបានលទ្ធផលគួរឱ្យកោតសរសើរ ។ប៉ុន្តែការយល់ដឹងរបស់មន្ត្រីនៅមានកំរិត អាស្រ័យហេតុនេះទាមទារឱ្យមានការបណ្តុះបណ្តាលផ្នែកបច្ចេកទេសជំនាញ បំពាក់សំភារៈឱ្យបានគ្រប់គ្រាន់ និងរៀបចំរចនាសម្ព័ន្ធ អ.ជ.ប.គ.ញ ឱ្យមានភាពរលូន ។

ចំពោះដំណាំកញ្ឆាយើងជឿជាក់ថា ក្រុមឧក្រិដ្ឋជនពិតជានៅបន្តព្យាយាមអូសទាញប្រជាកសិករខ្មែរយើងឱ្យធ្វើការដាំដុះតាមរយៈការផ្តល់ទុន គ្រាប់ពូជ ហើយប្រមូលទិញវិញក្នុងតំលៃមួយដែលមានប្រៀបជាងដំណាំស្របច្បាប់នានា ។ ភាពអសកម្មទាំងនេះកើតឡើង គឺអាស្រ័យដោយកត្តាជីវភាព ការប្រព្រឹត្តិដោយមានចេតនាលាក់បំបាំងពីអាជ្ញាធរមានសមត្ថកិច្ច និងមួយផ្នែកទៀតដោយមិនទាន់យល់ដឹងថា កញ្ឆាជាដំណាំគ្រឿងញៀនខុសច្បាប់ ។ ហេតុនេះ ទាមទារអោយមានវិធានការអប់រំអោយបានទូលំទូលាយ និងអនុវត្តច្បាប់អោយបានតឹងរ៉ឹង ។

ការផលិត ការចរាចរ ការជួញដូរគ្រឿងញៀន ជាពិសេសគ្រឿងញៀនប្រភេទ ATS មានលក្ខណៈស្មុគ្រស្មាញជាងគេដែលកំពុងត្រូវបានគេចោទប្រកាន់ថាបានផលិតនិងនាំចេញពីកម្ពុជា ។ទោះបីពុំមានភស្តុតាងគ្រប់គ្រាន់ដែលអាចបញ្ជាក់ថាមានការផលិតទ្រង់ទ្រាយធំដែលអាចឈានទៅធ្វើការនាំចេញបាន ប៉ុន្តែក៏មានសញ្ញាជាច្រើនដែលធ្វើអោយយើងមានការព្រួយបារម្ភ ។

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ជឿជាក់ថាស្ថិតិបណ្តោះអាសន្ននៃអ្នកប្រើបំពានគ្រឿងញៀនដែលបានរាយការណ៍ដោយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុងពិតជាមានភាពចន្លោះខ្វះខាត និងទាមទារនូវការធ្វើស្ថិតិមានលក្ខណៈវិទ្យាសាស្ត្រ និងការព្យាបាលជាបន្ទាន់ ។

ផ្អែកលើសភាពការណ៍ទាំងនេះ យើងអាចសន្និដ្ឋានថាបញ្ហាគ្រឿងញៀនកំពុងក្លាយជាសញ្ញាអាសន្នសំរាប់យើងទាំងអស់គ្នាដែលទាមទារអោយមានការដោះស្រាយរួមគ្នាយ៉ាងហ្មឹងម៉ាត់ និងទទួលខុសត្រូវខ្ពស់ ។ ការធ្វេសប្រហែស និងបណ្តែតបណ្តោយក្នុងការទប់ស្កាត់ ការបង្ក្រាប ការផ្តន្ទាទោស វានឹងអាចបណ្តាលអោយកម្ពុជាក្លាយជាកន្លែងដែលឧក្រិដ្ឋជនគ្រឿងញៀនបង្កើនសកម្មភាពខុសច្បាប់នានា ក្នុងពេលដែលពួកគេកំពុងទទួលរងនូវការគៀបសង្កត់យ៉ាងតឹងរ៉ឹងពីបណ្តាប្រទេសជិតខាង ។

# ជំពូក ២

# គោលការណ៍

# យុទ្ធសាស្ត្រ និងទិសដៅ

# ជំពូក II

# គោលការណ៍ យុទ្ធសាស្ត្រ និង ទិសដៅ

## ១. គោលការណ៍

ការរៀបចំផែនការស្តីពីការត្រួតពិនិត្យគ្រឿងញៀននេះ ត្រូវបានពិចារណាតាមគោលការណ៍ដូចខាងក្រោម :

- លក្ខណៈពហុវិស័យ និងភាពទូលំទូលាយគ្រប់ជ្រុងជ្រោយ
- ការចូលរួមពីសំណាក់សហគមន៍ និងក្រុមគ្រួសារ
- គោរពសិទ្ធិមនុស្ស

## ២. យុទ្ធសាស្ត្រ

រាជរដ្ឋាភិបាលកម្ពុជា អនុម័តយុទ្ធសាស្ត្រក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដូចខាងក្រោម:

- ការកាត់បន្ថយនិងឈានទៅលប់បំបាត់ទាំងស្រុងនូវតម្រូវការគ្រឿងញៀន
- ការកាត់បន្ថយនិងឈានទៅលប់បំបាត់ទាំងស្រុងនូវការផ្គត់ផ្គង់គ្រឿងញៀន
- ការអនុវត្តន៍ច្បាប់គ្រឿងញៀន
- ការកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន
- ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ

## ៣. ទិសដៅយូរអង្វែង

ដើម្បីអោយព្រះរាជាណាចក្រកម្ពុជាក្លាយជាសង្គមមួយដែលគ្មានគ្រឿងញៀននៅក្នុងតំបន់ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តយកទិសដៅយូរអង្វែងដូចខាងក្រោមនេះ :

- ការលុបបំបាត់ការប្រើបំពានគ្រឿងញៀន
- ការលុបបំបាត់ការចរាចរ និងការផលិត គ្រឿងញៀន
- ការលុបបំបាត់ដំណាំគ្រឿងញៀន
- ការគ្រប់គ្រងសារធាតុគីមីផ្សំ
- ការពង្រឹងប្រព័ន្ធច្បាប់ឱ្យមានប្រសិទ្ធិភាព

## ៤. ទិសដៅចំពោះមុខ

### ៤.១. ការពង្រឹងរចនាសម្ព័ន្ធរបស់ អ.ជ.ប.គ.ញ និងស្ថាប័នពាក់ព័ន្ធនានា

**៤.១.ក.** ពង្រឹងសមត្ថភាព អ.ជ.ប.គ.ញ និងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ រួមទាំងគណៈកម្មការត្រួត

ពិនិត្យគ្រឿងញៀនខេត្ត-ក្រុងចាប់ពីថ្នាក់ខេត្ត-ក្រុងដល់ស្រុក-ខ័ណ្ឌ។ ជាមួយនេះដែរក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន និងក្រុមការងាររបស់អាជ្ញាធរជាតិប្រយុទ្ធ-ប្រឆាំងគ្រឿងញៀននឹងត្រូវពង្រឹងបន្ថែមទៀត ដើម្បីអោយក្រុមការងារនេះអាចបំពេញភារកិច្ចបានល្អប្រសើរ។

**៤.១.ខ.** បង្កើត និងដាក់អោយដំណើរការនូវក្រុមការងារផ្សេងៗទៀត ដូចជា ក្រុមការងារអប់រំ និងបង្ការការពារ ការប្រើបំពានគ្រឿងញៀន និងក្រុមការងារតាមដានការអនុវត្តន៍ច្បាប់គ្រឿងញៀន។

**៤.១.គ.** ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ។

## ៤.២. ការកាត់បន្ថយតំរូវការគ្រឿងញៀន

**៤.២.ក.** លើកកំពស់ការយល់ដឹងជាសាធារណៈអំពីគ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀននៅក្នុងសង្គម។

**៤.២.ខ.** ជំរុញ និងលើកទឹកចិត្តឱ្យមានការចូលរួមពីផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាល និងសាសនាក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**៤.២.គ.** ដាក់បញ្ចូលបន្ថែមអំពីបញ្ហាគ្រឿងញៀន និងការរីករាលដាលជំងឺអេដស៍ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀនទៅក្នុងកម្មវិធីសិក្សាជាតិនៅគ្រប់កំរិតសិក្សាទាំងក្នុង និងក្រៅប្រព័ន្ធដោយរាប់បញ្ចូលទាំងការបណ្តុះបណ្តាលគ្រូបង្គោលផងដែរ។

**៤.២.ឃ.** ត្រួតពិនិត្យ តាមដាន និងវាយតំលៃជាប្រចាំនូវសកម្មភាពអប់រំ និងបង្ការទប់ស្កាត់ការប្រើបំពានគ្រឿងញៀន។

**៤.២.ង.** ផ្លាស់ប្តូរពត៌មាន និងបទពិសោធន៍ស្តីពីសកម្មភាពត្រួតពិនិត្យគ្រឿងញៀនជាមួយដៃគូពាក់ព័ន្ធ ។

**៤.២.ច.** ធានាផ្តល់នូវសុខភាព ការអប់រំ និងដំណោះស្រាយទូលំទូលាយស្របតាមលក្ខណៈច្បាប់ចំពោះអ្នកប្រើបំពានគ្រឿងញៀន ដើម្បីកាត់បន្ថយនូវតំរូវការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺហ៊ីវ/អេដស៍ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀនខុសច្បាប់។

## ៤.៣. ការកាត់បន្ថយដំណាំគ្រឿងញៀនខុសច្បាប់

**៤.៣.ក.** កសាងផែនការអភិវឌ្ឍន៍ការដាំដំណាំជំនួសដ៏មានប្រសិទ្ធិភាពមួយ ដើម្បីជំនួសដំណាំគ្រឿងញៀនខុសច្បាប់។

**៤.៣.ខ.** បង្កើនយុទ្ធនាការឃោសនាប្រឆាំងនឹងការដាំដុះដំណាំគ្រឿងញៀនខុសច្បាប់។

**៤.៣.គ.** លើកកំពស់ការយល់ដឹងជាសាធារណៈអំពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (ការដាំដុះដំណាំ

គ្រឿងញៀនខុសច្បាប់) ។

**៤.៣.ឃ.**សហការជាមួយបណ្តាប្រទេសជិតខាងក្នុងតំបន់ និងរៀនសូត្រអំពីបទពិសោធន៍ល្អៗទាក់ទងទៅនឹងការដាំដំណាំជំនួសស្របតាមស្ថានភាពភូមិសាស្ត្រប្រទេសកម្ពុជា ។

**៤.៤. ការត្រួតពិនិត្យ ការផលិត និងការចរាចរគ្រឿងញៀនខុសច្បាប់**

**៤.៤.ក.** បង្កើនកិច្ចសហប្រតិបត្តិការរវាងអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ ជាមួយស្ថាប័ននានាដែលពាក់-ព័ន្ធរួមមាននគរបាលជាតិ កងរាជអាវុធហត្ថជាតិ អង្គភាពគយនិងរដ្ឋាករ អង្គភាព កាំកុងត្រូល ។ល។ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ។

**៤.៤.ខ.** បន្តប្រើប្រាស់យន្តការបណ្តុះបណ្តាលតាមកុំព្យូទ័រ(CBT) ដើម្បីពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នគរបាលជាតិ កងរាជអាវុធហត្ថជាតិ គយ កាំកុងត្រូល និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ ។ ការបណ្តុះបណ្តាលផ្សេងៗទៀតនឹងត្រូវធ្វើទៅតាមមធ្យោបាយសមស្របនានា ដើម្បីឆ្លើយតបទៅនឹងសភាពការណ៍វិវត្តន៍នៃបទល្មើសគ្រឿងញៀន ។

**៤.៤.គ.** ពង្រឹងការិយាល័យទំនាក់ទំនងច្រកទ្វារព្រំដែន(BLO) ដោយសហការជាមួយបណ្តាប្រទេសជិតខាង និងឈានទៅបង្កើតបន្ថែមនៅតាមចំនុចសំខាន់ៗជាយុទ្ធសាស្ត្រដូចជាកំពង់ផែនិងព្រលានយន្តហោះ ។

**៤.៤.ឃ.** បង្កើនការត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន និងសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ(សារ-ធាតុវិកលវិទ្យា) ។

**៤.៤.ង.** លើកកំពស់សមត្ថភាពមន្ត្រីជំនាញរបស់មន្ទីរពិសោធន៍នៃអគ្គលេខាធិការដ្ឋានអ.ជ.ប.គ.ញ តាមរយៈការបណ្តុះបណ្តាលជំនាញ និងបំពាក់សំភារៈចាំបាច់សំរាប់ដំណើរការ ។

**៤.៤.ច.** បំផុសឱ្យមានការចូលរួមពីសាធារណជនក្នុងការផ្តល់ពត៌មានពាក់ព័ន្ធនឹងការផលិត ការចរាចរ ការជួញដូរ និងការប្រើបំពានគ្រឿងញៀនខុសច្បាប់ដោយមានការលើកទឹកចិត្ត ។

**៤.៤.ឆ.** លើកកំពស់សមត្ថភាពបំពេញការងារដល់អង្គភាពអនុវត្តច្បាប់តាមរយៈការផ្តល់សំភារៈបច្ចេកទេស និងការផ្តល់រង្វាន់លើកទឹកចិត្ត ។

**៤.៤.ជ.** បង្កើនកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជិតខាងក្នុងការទប់ស្កាត់ការហូរចូលគ្រឿងញៀន ។

**៤.៥. ការងារនីតិកម្ម**

**៤.៥.ក.** បន្តជំរុញការផ្តល់សច្ចាប័នក្នុងការសុំចូលជាសមាជិកអនុសញ្ញាគ្រឿងញៀនអន្តរជាតិទាំងបីឆ្នាំ១៩៦១ ឆ្នាំ ១៩៧១, និងឆ្នាំ ១៩៨៨ ។

**៤.៥.ខ.** បន្តជំរុញ និងធ្វើអោយបានសំរេចនូវវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន អនុក្រឹត្យ និងប្រកាសដូចខាងក្រោម :

១. អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មការប្រឆាំងការសំអាតប្រាក់ដែលបានមកពីជំនួញគ្រឿងញៀន ដែលជាសមត្ថកិច្ចធនាគារជាតិនៃកម្ពុជា ។

២. អនុក្រឹត្យស្តីពីការរឹបអូសទ្រព្យដែលបានមកពីជំនួញគ្រឿងញៀន និងការបង្កើតមូលនិធិជាតិសំរាប់ប្រយុទ្ធប្រឆាំងគ្រឿងញៀនដែលជាសមត្ថកិច្ច ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៣. អនុក្រឹត្យស្តីពីការជួយគ្នាទៅវិញទៅមកខាងតុលាការ ដែលជាសមត្ថកិច្ចក្រសួងយុត្តិធម៌។

៤. ប្រកាសស្តីពីការប្រគល់ដោយមានការឃ្លាំមើលដែលជាសមត្ថកិច្ចក្រសួងយុត្តិធម៌។

**៤.៥.គ.** រៀបចំអនុក្រឹត្យ និងបទបញ្ញត្តិនានា ដើម្បីអនុវត្តច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនអោយមានប្រសិទ្ធិភាព។

**៤.៥.ឃ.** ជំរុញការអនុវត្តន៍ច្បាប់ត្រួតពិនិត្យគ្រឿងញៀនបច្ចុប្បន្ននេះឱ្យមានប្រសិទ្ធិភាព។

## ៤.៦. ការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម

**៤.៦.ក.** រៀបចំគោលនយោបាយស្តីពីការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

**៤.៦.ខ.** រៀបចំមជ្ឈមណ្ឌលព្យាបាល ស្តារនីតិសម្បទា នៅភ្នំពេញនិងបណ្តាខេត្តមួយចំនួនដែលមានអ្នកញៀនគ្រឿងញៀនច្រើន។

**៤.៦.គ.** បង្កើតក្រុមពិគ្រោះយោបល់សំរាប់តាមដានអ្នកជំងឺនៅតាមសហគមន៍ និងគ្រួសារ ។

**៤.៦.ឃ.** លើកទឹកចិត្តឱ្យមានការចូលរួមពីសហគមន៍ ក្រុមគ្រួសារ អង្គការក្រៅរដ្ឋាភិបាល សាសនា និងអ្នកធ្លាប់ប្រើគ្រឿងញៀនក្នុងការអនុវត្តន៍កម្មវិធីព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មអ្នកប្រើគ្រឿងញៀនទៅក្នុងសង្គម។

# ជំពូក ៣

# កម្មវិធីសកម្មភាព

# គ្រូគពិនិត្យគ្រឿងញៀន

# ជំពូក III

# កម្មវិធីសកម្មភាពត្រួតពិនិត្យគ្រឿងញៀន

## ១. ការពង្រឹងរចនាសម្ព័ន្ធ អ.ជ.ប.គ.ញ និងបណ្តាស្ថាប័នពាក់ព័ន្ធ

### ១.១.ការពង្រឹងរចនាសម្ព័ន្ធ អ.ជ.ប.គ.ញ

**១.១.ក.** អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនពង្រឹងសមត្ថភាពមន្ត្រីរបស់អគ្គលេខាធិការដ្ឋានអ.ជ.ប.គ.ញ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីអោយមានសមត្ថភាពពេញលេញក្នុងការអនុវត្តន៍ការងារ តាមតួនាទី និងភារកិច្ច ។

**១.១.ខ.** បង្កើតមជ្ឈមណ្ឌលពតិមានគ្រឿងញៀននៅក្នុងរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ។

**១.១.គ.** រៀបចំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ទៅជាស្ថាប័នមួយដែលមានស្វ័យភាពរដ្ឋបាលនិងហិរញ្ញវត្ថុ

**១.១.ឃ.**ក្រសួងនិងស្ថាប័ន ដែលជាសមាជិកនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនត្រូវមានអង្គភាពមួយសំរាប់ធ្វើការងារត្រួតពិនិត្យគ្រឿងញៀនតាមតួនាទី និងភារកិច្ចរបស់ខ្លួន ។

**១.១.ង.** ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម(**UNODC)** គឺជាដៃគូដ៏មានសារៈសំខាន់ រួមជាមួយអង្គការ និងសហគមន៍អន្តរជាតិផ្សេងៗទៀត ដើម្បីជំរុញគំរោងផែនការនេះអោយដំណើរការប្រកបដោយប្រសិទ្ធិភាព ។

**១.១.ច.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវពង្រឹងគណៈកម្មការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុងតាមរយៈការធ្វើអោយដំណើរការប្រកបដោយប្រសិទ្ធិភាពនូវលេខាធិការដ្ឋាន និងឈានទៅបង្កើតគណៈកម្មការត្រួតពិនិត្យគ្រឿងញៀនស្រុក-ខ័ណ្ឌ ។ គណៈកម្មការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុងត្រូវមានកញ្ចប់ថវិកាសំរាប់ដំណើរការ ការងាររបស់ខ្លួនយោងតាមសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ០៩សសរ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០៤ ។

**១.១.ឆ.** អគ្គលេខាធិការដ្ឋានត្រូវមានអង្គភាពមួយសំរាប់តាមដានការងាររបស់គណៈកម្មការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង ។

**១.១.ជ.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវពង្រឹងក្រុមការងារអន្តរក្រសួងដែលមានស្រាប់តាមរយៈការពង្រឹងយន្តការការងារ និងការបណ្តុះបណ្តាល ។ ជាមួយគ្នានេះដែរ ក្រុមការងាររបស់ អ.ជ.ប.គ.ញ ក៏នឹងត្រូវរៀបចំអោយមានតួនាទីភារកិច្ចនិងបែបបទការងារដើម្បីដំណើរការអោយមានប្រសិទ្ធិភាព

**១.១.ឈ.**អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនត្រូវស្នើសុំថវិកាពីរាជរដ្ឋាភិបាលសំរាប់សាងសង់អាគារធ្វើការបន្ថែមទៀត ដើម្បីអោយសមស្របតាមការកើនឡើងនៃទំហំការងាររបស់អគ្គលេខាធិការដ្ឋាន។

**១.២.**ក្រុមការងារផ្សេងៗទៀតដែលមានសារៈសំខាន់ដល់ដំណើរការត្រួតពិនិត្យគ្រឿងញៀន ក៏នឹងត្រូវបង្កើតទៅតាមលំនាំដូចក្រុមការងារដែលមានស្រាប់ ដើម្បីឆ្លើយតបទៅនឹងការវិវត្តន៍នៃសភាពការណ៍។ ក្រុមការងារទាំងនោះរួមមានដូចជា ក្រុមការងារអប់រំបង្ការទប់ស្កាត់ការប្រើបំពានគ្រឿងញៀន ក្រុមការងារព្យាបាល និងក្រុមការងារតាមដានការអនុវត្តន៍ច្បាប់គ្រឿងញៀន ។ល។

**១.៣.**អ.ជ.ប.គ.ញ ខិតខំប្រឹងប្រែងដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសហគមន៍ផ្តល់ជំនួយទាំងអស់ទាំងក្នុងរូបភាពទ្វេភាគី និងពហុភាគីដោយមានការចូលរួមឧបត្ថម្ភពី UNODC។

## ២. ការកាត់បន្ថយតំរូវការគ្រឿងញៀន

### ២.១. ការលើកកំពស់ការយល់ដឹងជាសាធារណៈអំពីគ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀននៅក្នុងសង្គម

**២.១.ក.**អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវសំរបសំរួលជាមួយស្ថាប័នពាក់ព័ន្ធនានា អង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ សង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ដើម្បីលើកកំពស់ការយល់ដឹងជាសារធារណៈអំពីគ្រោះថ្នាក់នៃគ្រឿងញៀនពិសេសក្នុងចំណោមយុវវ័យ និងការរីករាលដាលជំងឺអេដស៍ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន។ សកម្មភាពទាំងនេះត្រូវរៀបចំជាយន្តការច្បាស់លាស់នៅគ្រប់បណ្តាស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន(ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ) ដើម្បីផ្សព្វផ្សាយដោយយកចិត្តទុកដាក់ ជាពិសេសនៅតាមកន្លែងសំខាន់ៗមួយចំនួនដូចជា រោងភាពយន្ត ក្លឹបកំសាន្ត សាលារៀន រោងចក្រ ទីផ្សារ និងទីប្រជុំជនសំខាន់ៗ...។ ក្រសួងស្ថាប័នដែលពាក់ព័ន្ធ សកម្មភាពខាងលើ និងខេត្ត-ក្រុង ត្រូវមានកញ្ចប់ថវិកាផ្ទាល់ខ្លួនសំរាប់រ៉ាប់រងការងារនេះ។

**២.១.ខ.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវសំរបសំរួលជាមួយស្ថាប័នពាក់ព័ន្ធនានាធ្វើសកម្មភាពកាត់បន្ថយគ្រោះថ្នាក់(Harm Reduction) ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន។ ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺអេដស៍ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននឹងពិចារណាអំពីការស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាលក្នុងការសំរួលអោយប្រើប្រាស់វិធីសាស្រ្ត និងបទពិសោធន៍ល្អៗដែលធ្លាប់បានអនុវត្តនៅតាមបណ្តាប្រទេសមួយចំនួនចំពោះក្រុមដែលប្រើបំពានគ្រឿងញៀនដោយការចាក់តាមសរសៃឈាម។ កិច្ចការនេះត្រូវស្ថិតក្រោមការត្រួតពិនិត្យ តាមដាន និងវាយតំលៃហ្មត់ចត់ពីអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ។

**២.១.គ.** ការវាយតំលៃអំពីលទ្ធផលនៃសកម្មភាពលើកកំពស់ការយល់ដឹងនឹងត្រូវធ្វើឡើងនៅក្នុងដំណាក់កាលមួយសមស្របដើម្បីពិនិត្យឡើងវិញពីគុណសម្បត្តិ និងគុណវិបត្តិ។ បទពិសោធន៍ទាំងឡាយដែលបានមកពីការវាយតំលៃនេះនឹងយកទៅអនុវត្តសំរាប់ការងារអប់រំ និងផ្សព្វផ្សាយនៅពេលអនាគត។ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ទទួលខុសត្រូវក្នុងការសំរបសំរួលបង្កើតយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំស្តីពីការរៀបចំឯកសារផ្សព្វផ្សាយនានាជាមួយស្ថាប័នពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិ-បាល។

**២.១.ឃ.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវសហការជាមួយប្រព័ន្ធផ្សព្វផ្សាយ ក្រសួងពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដើម្បីអោយក្រុមឃោសនាចល័តមានលទ្ធភាពធ្វើយុទ្ធនាការដោយទៀងទាត់នៅតាមចំណុចគោលដៅ។

**២.២. ជំរុញ និងលើកទឹកចិត្តឱ្យមានការចូលរួមពីគ្រប់ផ្នែកនៃសង្គមក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**២.២.ក.** ការលើកកំពស់ការយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀនគឺជាអាទិភាពនៃការងារទប់ស្កាត់ការរីករាលដាលនៃគ្រឿងញៀន។ ប្រព័ន្ធឃោសនាផ្សព្វផ្សាយរបស់រដ្ឋ និងឯកជនមានកាតព្វកិច្ចចូលរួមផ្សព្វផ្សាយដើម្បីលើកកំពស់ការយល់ដឹងជាសាធារណៈ។ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវចរចាឱ្យមានការចូលរួមពីផ្នែកឯកជន ជាពិសេសប្រព័ន្ធឃោសនាផ្សព្វផ្សាយ(ទូរទស្សន៍-វិទ្យុ) និងក្រុមហ៊ុនទូរគមនាគមន៍។

**២.២.ខ.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវរៀបចំអោយមានការប្រជុំជាទៀងទាត់ជាមួយអង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ព្រមទាំងអតីតអ្នកធ្លាប់ប្រើប្រាស់គ្រឿងញៀន ដើម្បីអោយពួកគេចូលរួមក្នុងសកម្មភាពលើកកំពស់ការយល់ដឹងជាសាធារណៈ។

**២.២.គ.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំអោយមានការប្រគុំតន្ត្រីអប់រំពីគ្រោះថ្នាក់នៃការប្រើបំពានគ្រឿងញៀន កម្មវិធីសំណួរនិងចំលើយពីបញ្ហាគ្រឿង-ញៀន ការឆ្លើយឆ្លងតាមទូរស័ព្ទដោយមិនបង់ថ្លៃសំរាប់កម្មវិធីនេះ ការផ្តល់រង្វាន់លើកទឹកចិត្តដល់អ្នកដែលបានចូលរួម និងវិធីសាស្ត្រដទៃទៀត ដើម្បីទាក់ទាញសាធារណជន ពិសេសដើម្បីបំផុសយុវវ័យអោយចូលរួមក្នុងកម្មវិធីទាំងអស់ខាងលើនេះ។

**២.៣.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវធ្វើការសំរបសំរួលជាមួយក្រសួងអប់រំ យុវជន និងកីឡា និងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីរៀបចំផែនការជាក់លាក់មួយក្នុងការបង្កើនកម្មវិធីអប់រំអំពីគ្រឿងញៀន និងការរីករាលដាលជំងឺអេដស៍ ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀនទៅក្នុងកម្មវិធីសិក្សាជាតិនៅ

គ្រប់កំរិតសិក្សាទាំងក្នុងនិងក្រៅប្រព័ន្ធ។ សកម្មភាពអប់រំទាំងឡាយនឹងត្រូវផ្តោតការយកចិត្តទុកដាក់ផងដែរ ជាពិសេសចំពោះវិធីសាស្ត្រធ្វើឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយាល្អជាវិជ្ជមាន និងភាពជឿជាក់ខ្លួនឯងក្នុងការដោះស្រាយបញ្ហាដោយម្ចាស់ការក្នុងចំណោមសិស្ស និងនិស្សិត។

**២.៤.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវរៀបចំយន្តការសំរាប់ត្រួតពិនិត្យ តាមដាន និងវាយតំលៃសកម្មភាពបង្ការទប់ស្កាត់ការប្រើបំពានគ្រឿងញៀន ដើម្បីធានាឱ្យកាន់តែមានប្រសិទ្ធិភាពខ្ពស់នៅពេលអនាគត។

**២.៤.ក.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវសហការជាមួយដៃគូពាក់ព័ន្ធនានា ដើម្បីសិក្សាស្រាវជ្រាវស្ទាបស្ទង់ជាទូទៅលើការប្រើបំពានគ្រឿងញៀន ក្នុងគោលបំណង :

ក/ ស្វែងយល់អំពីមូលហេតុ និងផលវិបាកនៃការប្រើបំពានគ្រឿងញៀន

ខ/ វាយតំលៃប្រសិទ្ធិភាពនៃកិច្ចអន្តរាគមន៍បង្ការ ទប់ស្កាត់ដែលបានអនុវត្ត និង

គ/ ស្វែងយល់ពីបញ្ហាថ្មីៗទាំងឡាយដែលពាក់ព័ន្ធនឹងការប្រើបំពានគ្រឿងញៀននិងជំងឺអេដស៍ ដែលតំរូវអោយមានអន្តរាគមន៍ជាបន្ទាន់។

**២.៤.ខ.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សហការជាមួយដៃគូពាក់ព័ន្ធនឹងធ្វើការអង្កេតជាទៀងទាត់ ដើម្បីតាមដាននិន្នាការនៃការប្រើបំពានគ្រឿងញៀន និងការរីករាលដាលជំងឺអេដស៍ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន។ តួលេខនៃការអង្កេតឆ្នាំដំបូងនឹងត្រូវបានប្រើប្រាស់ជាឯកសារយោងសំរាប់ធ្វើការប្រៀបធៀបទៅអនាគត។

**២.៥.** មជ្ឈមណ្ឌលពតិមានគ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវចងក្រងឯកសារព្រមទាំងផ្លាស់ប្តូរពតិមាន និងបទពិសោធន៍ស្តីពីសកម្មភាពត្រួតពិនិត្យគ្រឿងញៀន ជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាលដទៃទៀត។ អង្គភាពនេះនឹងសហការជាមួយនាយកដ្ឋាននីតិកម្ម អប់រំ និងបង្ការការពារព្រមទាំងនាយកដ្ឋានពាក់ព័ន្ធផ្សេងៗទៀត ដើម្បីស្វែងរកវិធីសាស្ត្រថ្មីៗដែលមានប្រសិទ្ធិភាពខ្ពស់ក្នុងការអប់រំសាធារណៈជន ជាពិសេសស្រទាប់យុវវ័យពីបញ្ហាគ្រឿងញៀន ។

## ៣. <u>ការកាត់បន្ថយដំណាំគ្រឿងញៀន</u>

### ៣.១. ការកសាងផែនការសកម្មភាពអភិវឌ្ឍន៍ការដាំដំណាំជំនួស

**៣.១.ក.** អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ ត្រូវសហការជាមួយក្រសួងពាក់ព័ន្ធនានាដូចជា ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងអង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធ ដើម្បីរៀបចំផែនការអភិវឌ្ឍន៍ដំណាំជំនួសដំណាំកញ្ឆានៅក្នុងប្រទេស(Alternative Development)។ ការសិក្សាអំពីតំបន់ដែលមានការដាំដុះដំណាំកញ្ឆា និងតំបន់ដែលអាចមាន

សក្ដានុពលក្នុងការដាំដុះកញ្ឆានឹងត្រូវធ្វើឡើងដោយក្រុមការងារមួយដែលនឹងត្រូវបង្កើតឡើងដោយ អ.ជ.ប.គ.ញ ។

**៣.១.ខ.** អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ ត្រូវសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីរៀបចំក្រុមបច្ចេកទេសមួយ ក្នុងគោលបំណងពន្យល់ណែនាំអំពីការអនុវត្តន៍កម្មវិធីដំណាំជំនួស នៅតាមសហគមន៍ និងគ្រួសារដែលពាក់ព័ន្ធ។ ឯកសារណែនាំពីបច្ចេកទេសនឹងត្រូវបានតាក់តែងឡើងសំរាប់ផ្សព្វផ្សាយដល់សហគមន៍ និងគ្រួសារដែលពាក់ព័ន្ធនោះ ។

**៣.១.គ.** ក្រសួងពាណិជ្ជកម្មត្រូវជួយស្វែងរកទីផ្សារក្នុង និងក្រៅប្រទេស ដើម្បីលក់កសិផល និងផលិតផលដែលផលិតដោយសហគមន៍និងគ្រួសារទាំងនោះ ។

**៣.១.ឃ.** អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនត្រូវបង្កើតនូវយន្តការអង្កេត និងវាយតំលៃដ៏មានប្រសិទ្ធិ-ភាពមួយ ដើម្បីតាមដានការដាំដំណាំគ្រឿងញៀនខុសច្បាប់ ។

**៣.១.ង.** ទស្សនកិច្ចសិក្សានឹងត្រូវបានរៀបចំឡើងសំរាប់មន្ត្រី អ.ជ.ប.គ.ញ និងមន្ត្រីនៃស្ថាប័នពាក់ព័ន្ធនានា ដើម្បីស្វែងយល់ពីបទពិសោធន៍ជាក់ស្ដែងរបស់បណ្ដាប្រទេសក្នុងតំបន់ ។

**៣.២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នជាតិ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនានាដើម្បីបង្កើនយុទ្ធនាការបង្ក្រាបដំណាំគ្រឿងញៀនខុសច្បាប់ ។

**៣.៣.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សហការជាមួយក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធ ត្រូវបញ្ចូលជំពូក និងមាត្រាខ្លះនៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនទៅក្នុងកម្មវិធីលើកកំពស់ការយល់ដឹងជាសាធារណៈ ដើម្បីធ្វើអោយប្រជាពលរដ្ឋមានការជ្រួតជ្រាបអំពីច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

**៣.៤.** ដោយមានការគាំទ្រពីអង្គការអន្តរជាតិ ជាពិសេសUNODC អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវធ្វើការស្រាវជ្រាវតាមប្រព័ន្ធអ៊ិនធឺណិត និងឯកសារនានា ដើម្បីដកស្រង់ចេញនូវវិធីសាស្ត្រដ៏មានប្រសិទ្ធិភាពបំផុតស្ដីពីការដាំដំណាំជំនួស និងធ្វើការចែករំលែកបទពិសោធន៍ទាំងនេះជូនដល់សហគមន៍ និងក្រុមគ្រួសារដែលពាក់ពន្ធ័។

## ៤. ការត្រួតពិនិត្យ ការផលិតនិងការចរាចរ គ្រឿងញៀនខុសច្បាប់

### ៤.១. ការបង្កើនកិច្ចសហប្រតិបត្តិការ ទប់ស្កាត់ការផលិត ការចរាចរ ការចែកចាយគ្រឿងញៀនខុសច្បាប់

**៤.១.ក.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយ នគរបាលជាតិ កងរាជអាវុធហត្ថជាតិ គយ កាំកុងត្រូល... និងអាជ្ញាធរខេត្ត-ក្រុង ព្រមទាំងស្រុក-ខ័ណ្ឌតាមរយៈការរៀបចំកិច្ចប្រជុំជាទៀងទាត់ដែលក្នុងពេលនោះអង្គភាពនីមួយៗនឹងត្រូវរាយការណ៍ អំពីការរីកចំរើនក្នុង

ការអនុវត្តន៍ និងបទពិសោធន៍ដែលបានជួបប្រទះ ។ របាយការណ៍ទាំងនេះនឹងត្រូវបញ្ជូនទៅមជ្ឈ-មណ្ឌលពត៌មានគ្រឿងញៀននៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សំរាប់រក្សាទុកធ្វើការវិភាគ និងផ្សព្វផ្សាយ ។

**៤.១.ខ.** គំរូរបាយការណ៍រួមមួយនឹងត្រូវបង្កើតឡើងដោយមានការឯកភាពគ្នា ដើម្បីងាយស្រួលដល់ការរក្សាទុក ការធ្វើរបាយការណ៍ និងការវិភាគ ។

## ៤.២. ការបន្តប្រើប្រាស់យន្តការបណ្តុះបណ្តាលតាមកុំព្យូទ័រ (CBT) ដើម្បីពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់

**៤.២.ក.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវស្វែងរកការគាំទ្រពីប្រទេសអ្នកផ្តល់ជំនួយនានាពិសេសអង្គការ UNODC ដើម្បីបន្តប្រើប្រាស់ និងពង្រីកយន្តការបណ្តុះបណ្តាលដោយកុំព្យូទ័រ (CBT) សំដៅពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ។ ជាមួយគ្នានេះ ការបណ្តុះបណ្តាលតាមវិធីផ្សេងៗទៀតក៏នឹងត្រូវយកមកអនុវត្តសំរាប់មន្ត្រីអនុវត្តច្បាប់ និងអាជ្ញាធរមានសមត្ថកិច្ចទាំងអស់ផងដែរ ដើម្បីទប់ស្កាត់នូវការវិវត្តន៍យ៉ាងឆាប់រហ័សនិងស្មុគ្រស្មាញនៃបណ្តាញឧក្រិដ្ឋជន ។ ការផ្តល់នូវឧបករណ៍សំភារៈ និងមធ្យោបាយទំនាក់ទំនងនឹងត្រូវបានយកចិត្តទុកដាក់ផងដែរ ។

**៤.២.ខ.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវវាយតំលៃពីតម្រូវការរបស់បណ្តាស្ថាប័នអនុវត្តច្បាប់គ្រឿងញៀននានា ពិសេសនគរបាលប្រឆាំងគ្រឿងញៀន និងកសាងផែនការឆ្លើយតបទៅនឹងកង្វះខាតទាំងនេះ ។

**៤.២.គ.** ការវាយតំលៃពីប្រសិទ្ធិភាពនៃការបណ្តុះបណ្តាលតាមកុំព្យូទ័រនឹងត្រូវធ្វើឡើងដោយទៀងទាត់តាមរយៈការពិនិត្យពិចារណាលើលទ្ធផលនៃការរឹបអូសគ្រឿងញៀន និងការចាប់ខ្លួនឧក្រិដ្ឋជន ។

## ៤.៣. ការពង្រឹងនិងពង្រីក ការិយាល័យទំនាក់ទំនងព្រំដែន (BLO)

**៤.៣.ក.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវស្វែងរកការគាំទ្រពីបណ្តាប្រទេសផ្តល់ជំនួយនានា ពិសេស UNODC ដើម្បីបន្តពង្រឹងការិយាល័យទំនាក់ទំនងព្រំដែនបច្ចុប្បន្ន ដោយសហប្រតិបត្តិការជាមួយប្រទេសជិតខាង និងពង្រីកទៅកាន់តំបន់ព្រំដែនយុទ្ធសាស្ត្រផ្សេងៗទៀតដូចជា កំពង់ផែអន្តរជាតិ អាកាសយានដ្ឋានអន្តរជាតិ និងបណ្តាខេត្តព្រំដែនតាមដងទន្លេមេគង្គ ។

**៤.៣.ខ.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដោយមានការឧបត្ថម្ភគាំទ្រពី**UNODC** ឬសហគមន៍អន្តរជាតិនានាត្រូវបង្កើតប្រព័ន្ធផ្តល់ពត៌មានរហ័ស(Early Warning System) ដោយរាប់បញ្ចូលទាំងពិធីសារ និងគោលការណ៍ណែនាំសំរាប់ការិយាល័យទំនាក់ទំនងព្រំដែន និងបណ្តាញពាក់ព័ន្ធរបស់ខ្លួនរួមទាំងស្ថាប័នដែលពាក់ព័ន្ធនៅក្នុងនិងក្រៅប្រទេសសំរាប់តាមដានករណីការប្រគល់ដោយមានការឃ្លាំមើល

(Controlled Deliveries) និងករណីសង្ស័យដទៃទៀត។ កសាងមូលដ្ឋានទិន្នន័យស្តីពីឧក្រិដ្ឋជន និងជនសង្ស័យដើម្បីធ្វើការផ្លាស់ប្តូរពត៌មាន និងជូនដំណឹងដល់ដៃគូដែលពាក់ព័ន្ធទាំងក្នុងប្រទេស និងលើសកលលោក។

**៤.៤. ការគ្រប់គ្រងសារធាតុគីមីផ្សំគ្រឿងញៀន និងសារធាតុញៀនដែលប៉ះពាល់សរសៃប្រសាទ**

**៤.៤.ក.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងសហការជាមួយ អាជ្ញាធរមានសមត្ថកិច្ច ក្រសួងសុខាភិបាល ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល កងកំលាំងប្រដាប់អាវុធ គយ កាំកុងត្រូល មន្ត្រីBLO និងគំរោងអនុតំបន់ដែលពាក់ព័ន្ធរបស់UNODC ដើម្បីពង្រឹងការគ្រប់គ្រងសារធាតុគីមីផ្សំដែលបានផលិត នាំចូល-នាំចេញ ប្រើប្រាស់ ស្តុកទុក ដាក់លក់ និងចែកចាយដោយបណ្តាក្រុមហ៊ុន។ កិច្ចការនេះមិនពាក់ព័ន្ធដល់នីតិវិធី នៃការសំរេចអោយនាំចូលសំរាប់ក្រុមហ៊ុនវិនិយោគដែលមានក្រុមការងារអន្តរក្រសួងត្រួតពិនិត្យ សារធាតុគីមីផ្សំដោយឡែកនោះទេ។

**៤.៤.ខ.** ការបណ្តុះបណ្តាលលើជំនាញត្រួតពិនិត្យសារធាតុគីមីផ្សំនឹងត្រូវធ្វើឡើងអោយបានដល់គ្រប់មន្ត្រីអនុវត្តច្បាប់នៅតាមតំបន់សំខាន់ៗ។

**៤.៥. ការលើកកំពស់សមត្ថភាពជំនាញមន្ត្រីមន្ទីរពិសោធន៍គ្រឿងញៀន**

**៤.៥.ក.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដោយមានការជួយគាំទ្រពីអង្គការUNODC នឹងស្វែងរកមូលនិធិពីបណ្តាប្រទេសផ្តល់ជំនួយ និងអង្គការអន្តរជាតិនានា ដើម្បីគាំទ្រដល់ការលើកកំពស់សមត្ថភាពអ្នកបច្ចេកទេសមន្ទីរពិសោធន៍គ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ តាមរយៈការបណ្តុះបណ្តាលនៅក្នុង និងក្រៅប្រទេស។

**៤.៥.ខ.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដោយមានការជួយគាំទ្រពីអង្គការUNODC នឹងស្វែងរកមូលនិធិពីបណ្តាប្រទេសផ្តល់ជំនួយនិងអង្គការអន្តរជាតិ ដើម្បីលើកកំពស់និងផ្គត់ផ្គង់សំភារៈបរិក្ខារចាំបាច់នានាដល់មន្ទីរពិសោធន៍គ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដែលមានស្រាប់ដោយគិតទាំងការធានាសុវត្ថិភាព និងសុខភាពរបស់មន្ត្រីដែលបំរើការងារនៅទីនោះ។

**៤.៥.គ.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សហការជាមួយអង្គការUNODC ដើម្បីផ្តល់នូវសារធាតុញៀនគំរូទាំងឡាយដល់មន្ទីរពិសោធន៍គ្រឿងញៀនរបស់ខ្លួន។

**៤.៥.ឃ.** អ.ជ.ប.គ.ញ ដោយមានការជួយគាំទ្រពី UNODC នឹងបង្កើតមន្ទីរពិសោធន៍ខ្នាតតូចនៅតាមតំបន់អាទិភាពមួយចំនួន។ មន្ទីរពិសោធន៍ទាំងនោះនឹងស្ថិតនៅក្រោមការណែនាំបច្ចេកទេសពីមន្ទីរពិសោធន៍របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ។

**៤.៦.ការបំផុសឱ្យមានការចូលរួមផ្តល់ពត៌មានពីសាធារណជន អំពីការផលិត ការចរាចរ ការជួញដូរគ្រឿងញៀន**

ខុសច្បាប់

**៤.៦.ក.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងអាជ្ញាធរមានសមត្ថកិច្ចនានា ត្រូវលើកទឹកចិត្តអោយមានការចូលរួមពីសាធារណជនក្នុងការផ្តល់ពត៌មានដែលទាក់ទងទៅនឹងការចរាចរ ការផលិត ការស្តុកទុក និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ។ សុវត្ថិភាព និងការសំងាត់របស់អ្នកផ្តល់ពត៌មាននឹងត្រូវបានធានាដោយអាជ្ញាធរមានសមត្ថកិច្ចស្របតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**៤.៦.ខ.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវតាមដាននូវគ្រប់ករណីគ្រឿងញៀនដែលបានបញ្ជូនទៅតុលាការវិនិច្ឆ័យទោសហើយមជ្ឈមណ្ឌលពត៌មានគ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋានអ.ជ.ប.គ.ញ នឹងត្រូវទទួលរ៉ាប់រងធ្វើរបាយការណ៍ និងរក្សាទុកជាឯកសារចំពោះលទ្ធផលនៃការវិនិច្ឆ័យលើករណីនីមួយៗ។ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សហការជាមួយក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធជំរុញការពង្រឹងសមត្ថភាពមន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់នានា (ចៅក្រម ព្រះរាជអាជ្ញា នគរបាល កងរាជអាវុធហត្ថ គយ...) ដើម្បីអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀនឱ្យមានប្រសិទ្ធិភាព។

**៤.៧.**ដោយមានការឧបត្ថម្ភគាំទ្រពីUNODC និងសហគមន៍ផ្តល់ជំនួយនានា អ.ជ.ប.គ.ញ ត្រូវផ្តល់នូវមធ្យោបាយសំភារៈដែលមានសារៈសំខាន់សំរាប់ការងារស៊ើបអង្កេតដល់ស្ថាប័នអនុវត្តន៏ច្បាប់នានា។

**៤.៨.**អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវបង្កើនកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសនានា ជាពិសេស បណ្តាប្រទេសជិតខាង ក្នុងការទប់ស្កាត់គ្រឿងញៀនខុសច្បាប់។

## ៥. <u>ការងារនីតិកម្ម</u>

**៥.១.**ក្រសួងយុត្តិធម៌សហការជាមួយអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ជំរុញការធ្វើវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងលើកកំពស់ការយល់ដឹងជាសាធារណៈដល់មន្ត្រីរាជការ និងសង្គមស៊ីវិលអំពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងអនុសញ្ញាអន្តរជាតិទាំងបី ពិសេសតាមរយៈសិក្ខាសាលា ។ បទបញ្ញត្តិពិសេសស្តីពីសិទ្ធិរបស់អ្នកញៀន ដែលទាក់ទងនឹងការព្យាបាលការស្តារនីតិសម្បទាក៏ត្រូវបានលើកឡើងបញ្ជាក់នៅក្នុងសិក្ខាសាលាផងដែរ។UNODC និងភាគីផ្តល់ជំនួយនានាគឺជាដៃគូដ៏សំខាន់ក្នុងការអនុវត្តន៏នូវកម្មវិធីនេះ

**៥.២.**បន្ទាប់ពីអនុសញ្ញាទាំងបីត្រូវបានផ្តល់សច្ចាប័នហើយ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវជំរុញឱ្យបណ្តាស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលអនុវត្តតាមស្មារតីអនុសញ្ញាទាំងបីអោយមានប្រសិទ្ធិភាព ។ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននឹងរាយការណ៍ជូនទៅរាជរដ្ឋាភិបាលកម្ពុជា ក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿង-ញៀនអន្តរជាតិ (INCB) អំពីភាពជឿនលឿននៃការអនុវត្តន៍តាមស្មារតីនៃអនុសញ្ញាទាំងនោះ។

**៥.៣.**អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវធ្វើការពិគ្រោះយោបល់ជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធនានាដើម្បីជំរុញអោយសេចក្តីព្រាង អនុក្រឹត្យ និងប្រកាស(ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន) ឆាប់បានចូលជាធរមាន ដូចជា :

ក/ អនុក្រឹត្យ ស្តីពីការបង្កើតគណៈកម្មការប្រឆាំងនឹងការសំអាតប្រាក់ដែលបានមកពីជំនួញគ្រឿងញៀន។

ខ/ អនុក្រឹត្យ ស្តីពីការរឹបអូសទ្រព្យដែលបានមកពីជំនួញគ្រឿងញៀន និងមូលនិធិជាតិសំរាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលជាសមត្ថកិច្ចក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

គ/ អនុក្រឹត្យ ស្តីពីការជួយគ្នាទៅវិញទៅមកខាងតុលាការ ដែលជាសមត្ថកិច្ចក្រសួងយុត្តិធម៌។

ឃ/ ប្រកាស ស្តីពីការប្រគល់ដោយមានការឃ្លាំមើល ដែលជាសមត្ថកិច្ចក្រសួងយុត្តិធម៌។

**៥.៤.**អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវសហការជាមួយក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និងស្ថាប័នអនុវត្តច្បាប់ដទៃទៀត ដើម្បីសិក្សាលើការប្រើប្រាស់ច្បាប់នានាដែលមានជាធរមាន (ក្រៅពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន)ក្នុងការទប់ស្កាត់ឱ្យមានប្រសិទ្ធិភាពចំពោះបទឧក្រិដ្ឋដែលទាក់ទងទៅនឹងគ្រឿងញៀន។

## ៦. ការព្យាបាល ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀន

**៦.១.**អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវសហការជាមួយក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងស្ថាប័នពាក់ព័ន្ធនានារៀបចំសេចក្តីព្រាងគោលនយោបាយមួយ ស្តីពីការព្យាបាល ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀនដើម្បីដាក់ជូនរាជរដ្ឋាភិបាលអនុម័ត ។ ថវិកាសំរាប់ដំណើរការ ការព្យាបាល ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀន ត្រូវស្នើទៅរាជរដ្ឋាភិបាលដោយស្ថាប័នដែលទទួលបន្ទុកការងារនេះ។ អ.ជ.ប.គ.ញ នឹងសហការជាមួយ UNODC អំពាវនាវដល់សហគមន៍អន្តរជាតិ ដើម្បីស្វែងរកការជួយឧបត្ថម្ភជ្រោមជ្រែងបន្ថែមទៀតសំរាប់កិច្ចដំណើរការខាងលើនេះ។

### ៦.២. ការរៀបចំរចនាសម្ព័ន្ធ មជ្ឈមណ្ឌលព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម

**៦.២.ក.** អ.ជ.ប.គ.ញ ត្រូវស្នើសុំគោលការណ៍ទៅរាជរដ្ឋាភិបាល ដើម្បីរៀបចំបង្កើតមជ្ឈមណ្ឌលព្យាបាល ស្តារនីតិសម្បទាជាផ្លូវការរបស់រដ្ឋនៅខេត្ត-ក្រុងអាទិភាព ដោយដាក់មជ្ឈមណ្ឌលនេះអោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង។

**៦.២.ខ.**ការបង្កើតមជ្ឈមណ្ឌលព្យាបាល ស្តារនីតិសម្បទាអ្នកញៀននៅតាមខេត្ត-ក្រុង ត្រូវយកចិត្តទុកដាក់ដល់ការរៀបចំរចនាសម្ពន្ធ័ ការជ្រើសរើសបុគ្គលិក ព្រមទាំងរៀបចំបទបញ្ញត្តិនានាដែលចាំបាច់សំរាប់

កិច្ចដំណើរការរបស់មជ្ឈមណ្ឌលដោយមានការចូលរួមពីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ អង្គការUNODC និងស្ថាប័នពាក់ព័ន្ធផ្សេងៗ។

**៦.២.គ.** ជំហានដំបូង អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងសហការជិតស្និទ្ធ ជាមួយក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា អាជ្ញាធរមូលដ្ឋាន អង្គការUNODC និងអង្គការអន្តរជាតិនានា ដើម្បីរៀបចំបង្កើតនិងស្តារហេដ្ឋារចនាសម្ព័ន្ធសមស្របសំរាប់សេវាកម្មទាំងនេះនៅទីក្រុងភ្នំពេញ និងនៅខេត្តអាទិភាពមួយចំនួន។

**៦.២.ឃ.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវសហការជាមួយក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អង្គការUNODC អង្គការក្រៅរដ្ឋាភិបាល និងអ្នកជំនាញនានា ដើម្បីរៀបចំបណ្តុះបណ្តាលដល់បុគ្គលិកដែលបំរើការក្នុងមជ្ឈមណ្ឌលនូវជំនាញសំខាន់ៗដូចជា ការជួយជាបឋម ការពិគ្រោះយោបល់ ការបន្សាបជាតិពុល វិធីសាស្ត្រនៃការព្យាបាលបញ្ហាគ្រឿងញៀននិងជំងឺអេដស៍ ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាលជម្ងឺផ្លូវចិត្ត ការផ្តល់បំនិនជីវិត និងការធ្វើសមាហរណកម្មចូលក្នុងសង្គម។

**៦.២.ង.** អ.ជ.ប.គ.ញ ត្រូវបង្កើតក្រុមការងារផ្សេងៗដែលទទួលរ៉ាប់រងលើវិស័យបច្ចេកទេសដូចជាវិធីសាស្ត្រនៃការព្យាបាល ការបន្សាបជាតិពុល...ដោយមានការគាំទ្រពីUNODC។ ការពិភាក្សា និងការពិគ្រោះយោបល់ជាមួយនឹងអ្នកមានវិជ្ជាជីវៈក្នុងនិងក្រៅប្រទេស នឹងត្រូវអនុវត្តដោយក្រុមការងារទាំងនេះដើម្បីស្វែងរកគោលការណ៍ឯកភាពជាតិទៅលើវិធីសាស្ត្រព្យាបាល ការបន្សាបជាតិពុល...សំរាប់ដាក់អោយប្រើនៅតាមមជ្ឈមណ្ឌលនានា។

## ៦.៣. ការរៀបចំបង្កើតក្រុមពិគ្រោះយោបល់អ្នកញៀនគ្រឿងញៀន

**៦.៣.ក.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវសហការជាមួយក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អង្គការក្រៅរដ្ឋាភិបាលនានា និងអាជ្ញាធរមូលដ្ឋាន ដើម្បីបង្កើតក្រុមពិគ្រោះយោបល់សំរាប់ចុះទៅជួយអ្នកញៀនគ្រឿងញៀននៅតាមសហគមន៍ និងគ្រួសារ ។

**៦.៣.ខ.** ដោយមានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន ក្រុមពិគ្រោះយោបល់ត្រូវលើកទឹកចិត្តអោយមានការចូលរួមពី សហគមន៍ ក្រុមគ្រួសារ អ្នកធ្លាប់ប្រើគ្រឿងញៀន និងអង្គការក្រៅរដ្ឋាភិបាលក្នុងការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម។ ការចូលរួមនេះនឹងត្រូវបានចាត់ទុកជាផ្នែកសំខាន់មួយនៃកម្មវិធីព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន ។

## ៦.៤. ការលើកកំពស់សមត្ថភាពមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទា

**៦.៤.ក.** មជ្ឈមណ្ឌលត្រូវមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងមជ្ឈមណ្ឌលដទៃទៀតនៅក្នុងតំបន់ និង សកលលោកដោយមានការជួយសំរបសំរួលពីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងអង្គការUNODC ដើម្បីលើកកំពស់សមត្ថភាពបច្ចេកទេសរបស់បុគ្គលិកមជ្ឈមណ្ឌល។

**៦.៤.ខ.** ដើម្បីលើកកំពស់សមត្ថភាពនិងចំណេះដឹងរបស់បុគ្គលិក មជ្ឈមណ្ឌលត្រូវមានកម្មវិធីទស្សនកិច្ចសិក្សា ឬផ្លាស់ប្តូរបទពិសោធន៍នៅមជ្ឈមណ្ឌលដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាក្នុងតំបន់ដោយ មានការគាំទ្រពី អ.ជ.ប.គ.ញ, UNODC និងសហគមន៍អន្តរជាតិ។

# ជំពូក ៤

# គំរូការធនធាន និងហិរញ្ញវត្ថុ

# ជំពូក IV
# តំរូវការធនធាន និង ហិរញ្ញវត្ថុ

## ១. តំរូវការធនធានមនុស្ស

ការលើកកំពស់សមត្ថភាពមន្ត្រីជំនាញរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅតែជាកិច្ចការដ៏សំខាន់មួយដែលត្រូវទាមទារអោយមានការយកចិត្តទុកដាក់ដើម្បីធានាថា សកម្មភាពត្រួតពិនិត្យគ្រឿងញៀនត្រូវបានស្ថិតក្រោមការចាត់ចែងគ្រប់គ្រង និងសំរបសំរួលដ៏មានប្រសិទ្ធិភាព។

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ មានបុគ្គលិកមួយចំនួនសំរាប់បំរើការងារនៅតាមបណ្តានាយកដ្ឋាន និងការិយាល័យរបស់ខ្លួន។ ភាគច្រើននៃបុគ្គលិកទាំងនោះ ត្រូវការបណ្តុះបណ្តាលជំនាញមូលដ្ឋានជាច្រើនដូចជា កុំព្យូទ័រ ភាសាអង់គ្លេស ការងារគ្រប់គ្រង ការរៀបចំអនុវត្តនិងគ្រប់គ្រងគំរោង ការតាមដាននិងវាយតំលៃ ការស្វែងរកការគាំទ្រ ការស្វែងរកថវិកា ការទំនាក់ទំនង និងការសរសេររបាយការណ៍។ល។

បន្ថែមលើនេះទៀត មានការចាំបាច់ក្នុងការកំណត់តួនាទីភារកិច្ច និងការទទួលខុសត្រូវអំពីមុខងាររបស់នាយកដ្ឋាន ការិយាល័យ និងបុគ្គលិកនីមួយៗនៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ឱ្យបានច្បាស់លាស់។ សិក្ខាសាលាមួយនឹងត្រូវបានរៀបចំដោយអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដើម្បីសំរេចបានគោលដៅនេះ។

សំខាន់ជាងនេះទៀតត្រូវពង្រឹងទំនាក់ទំនងរវាងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងក្រសួងស្ថាប័នផ្សេងៗដែលជាសមាជិក។ បញ្ហានេះក៏ត្រូវការផងដែរនូវការពង្រឹង និងការធ្វើអោយប្រសើរឡើងជាពិសេសកិច្ចសហប្រតិបត្តិការរួម ការទំនាក់ទំនង ការចែករំលែកពតិមាន និងការរាយការណ៍។ បន្ថែមលើនេះទៀត សមត្ថភាពរបស់មន្ត្រីជំនាញនានាដូចជា នគរបាល កងរាជអាវុធហត្ថ គយ និងភ្នាក់ងារអនុវត្តច្បាប់ផ្សេងៗទៀតក៏ទាមទារអោយមានការពង្រឹងដូចគ្នាផងដែរ។ ការបណ្តុះបណ្តាលជំនាញជាក់លាក់ដូចដែលបានធ្វើតាមរយៈយន្តការCBT និងការបណ្តុះបណ្តាលជំនាញផ្សេងៗទៀតទាំងនៅក្នុងឬក្រៅប្រទេសនឹងជួយពង្រឹងប្រសិទ្ធិភាពអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ។ ជំនួយពីខាងក្រៅនៅតែជាតំរូវការចាំបាច់យ៉ាងខ្លាំងសំរាប់រាល់ជំហានដូចដែលបានបញ្ជាក់ខាងលើ ។

## ២. តំរូវការទីតាំង និងសំភារៈផ្សេងៗ

បច្ចុប្បន្ន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ពុំទាន់មានទីតាំងល្មមគ្រប់គ្រាន់សំរាប់បុគ្គលិកទាំងអស់ដើម្បីបំពេញភារកិច្ចដូចមានចែងក្នុងអាណត្តិនៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នោះទេ អាស្រ័យហេតុនេះអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ មានគំរោងពង្រីកទីតាំងរបស់ខ្លួនឱ្យបានសមស្របនាអនាគតឆាប់ៗខាងមុខនេះ។

ការបំពាក់សំភារៈការិយាល័យព្រមទាំងឧបករណ៍បច្ចេកទេសតាមនាយកដ្ឋាន និងការិយាល័យនីមួយៗអោយបានគ្រប់គ្រាន់ក៏ជាតំរូវការចាំបាច់ផងដែរ។ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ គ្រោងបំពាក់ឱ្យបានគ្រប់គ្រាន់នូវបណ្តាញ ទូរស័ព្ទ ទូរសារ ប្រព័ន្ធអ៊ីនធឺណិត និងសារអេឡិចត្រូនិក ដើម្បីដំណើរការគ្រប់គ្រាន់តាមតំរូវការប្រចាំថ្ងៃ និងជំរុញល្បឿនការងារ។

## ៣. តំរូវការថវិកាសរុប (ឧបសម្ព័ន្ធ ១)

## ៤. បញ្ហាអាទិភាព និងតំរូវការថវិកា (ឧបសម្ព័ន្ធ ១)

## ៥. ផែនការសកម្មភាពលំអិតប្រចាំឆ្នាំ និងថវិកា

នៅពេលដែលផែនការជាតិ៥ឆ្នាំ (២០០៥ដល់ឆ្នាំ២០១០ត្រូវបានអនុម័ត) អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សហការ ជាមួយស្ថាប័នពាក់ព័ន្ធនានាត្រូវធ្វើផែនការសកម្មភាពលំអិតប្រចាំឆ្នាំសំរាប់ឆ្នាំនីមួយៗ។ ផែនការសកម្មភាពលំអិតប្រចាំឆ្នាំនោះរួមមាន :

ក/ ការរំពឹងទុកពីទិន្នផល

ខ/ សកម្មភាពលំអិត

គ/ នាយកដ្ឋាន/ការិយាល័យ និងអ្នកទទួលរ៉ាប់រងក្នុងការអនុវត្តនីសកម្មភាពច្បាស់លាស់ណាមួយ

ឃ/ ថវិកាប៉ាន់ស្មាន

ង/ តារាងពេលវេលា

ជាមួយគ្នានេះ ក្នុងកិច្ចដំណើរការផែនការជាតិ វិធីសាស្ត្រនៃការចូលរួមដ៏ច្បាស់លាស់មួយរបស់នាយកដ្ឋាន ការិយាល័យ និងបុគ្គលិកសំខាន់ៗត្រូវបានរៀបចំឡើងផងដែរនៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំនីមួយៗក្នុងនោះរួមទាំងកិច្ចប្រជុំផ្ទៃក្នុងនានា និងសិក្ខាសាលាមួយចំនួន។

បន្ទាប់ពីបានត្រួតពិនិត្យជាចុងក្រោយ ផែនការសកម្មភាពលំអិតប្រចាំឆ្នាំនឹងត្រូវដាក់ជូនប្រធាន អ.ជ.ប.គ.ញ ដើម្បីអនុម័ត។ ផែនការសកម្មភាពលំអិតប្រចាំឆ្នាំ ដែលត្រូវបានអនុម័តហើយនេះនឹងត្រូវបានអនុវត្ត។ ជាចុងក្រោយគឺលទ្ធភាពនៃការដកថវិកាជាតិយកមកប្រើប្រាស់ឱ្យបានទាន់ពេលវេលា ដែលជាកត្តាកំណត់ដ៏សំខាន់បំផុតសំរាប់ដំណើរការសកម្មភាពនានា។

ជាការពិតណាស់ ផែនការសកម្មភាពប្រចាំឆ្នាំអាចនឹងធ្វើការកែតំរូវ ពិសេសបន្ទាប់ពីឆ្នាំទី២ឬឆ្នាំទី៣ (២០០៧-២០០៨) ដោយហេតុថាផែនការជាតិទាំងមូលក៏អាចប្រែប្រួលផងដែរ ដោយយោងទៅតាមលទ្ធផលនៃការវាយតំលៃនៅពាក់កណ្តាលគំរោងនៃផែនការជាតិ។

ប្រសិទ្ធិភាពក្នុងការសំរេចផែនការប្រចាំឆ្នាំនីមួយៗ ពឹងផ្អែកភាគច្រើនទៅលើ:

ក/ ការបែងចែកច្បាស់លាស់ អំពីភារកិច្ចរបស់នាយកដ្ឋាន ការិយាល័យឬបុគ្គលិកនានា

ខ/ មានមន្ត្រីដែលពាក់ព័ន្ធគ្រប់គ្រាន់

គ/ សមត្ថភាពរបស់បុគ្គលិកទាំងនោះ

ឃ/ មានថវិកាគ្រាប់គ្រាន់

ផ្អែកលើមូលដ្ឋាននៃការវាយតំលៃថវិកាសរុប ផែនការជាតិត្រូវបានរំពឹងថា នឹងត្រូវការថវិកាសរុបប្រមាណជាង ៧.000.000(ប្រាំពីរលាន)ដុល្លារអាមេរិកសំរាប់អនុវត្តសកម្មភាពទាំងអស់(ចំនួននេះមិនរួមបញ្ចូលតំលៃផ្ទាល់ និងប្រយោលដែលបានមកពីបណ្តាស្ថាប័នម្ចាស់ជំនួយអន្តរជាតិឬអង្គការសហប្រជាជាតិផ្សេងៗ ការចំណាយផ្នែករដ្ឋ-បាលប្រចាំឆ្នាំរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងការពង្រីកទីតាំងរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ឡើយសូមអានឧបសម្ព័ន្ធ១សំរាប់ពតិមានបន្ថែមស្តីពីថវិកា)។ តំលៃសរុបនេះអាចនឹងត្រូវបានផ្លាស់ប្តូរយោលទៅតាមការបង្កើតមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទានៅភ្នំពេញនិងនៅតាមបណ្តាខេត្តមួយចំនួន រួមបញ្ចូលទាំងផែនការពង្រីកនៅក្នុងបណ្តាខេត្តផ្សេងៗទៀត ដូចដែលបានគ្រោងរួចហើយដោយ អ.ជ.ប.គ.ញ និងUNODC។

UNODC នៅកម្ពុជាដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដើម្បីអនុវត្តផែនការជាតិ។ ក្នុងករណីជួបការលំបាកបំផុតដែលថវិការដ្ឋាភិបាលមិនត្រូវបានអនុម័តតាមពេលកំណត់ឬមិនអាចយកមកប្រើប្រាស់បាន ការិយាល័យUNODC ក្នុងប្រទេសកម្ពុជានឹងសហការយ៉ាងជិតស្និទ្ធជាមួយ អ.ជ.ប.គ.ញ ក្នុងការស្វែងរកមធ្យោបាយនានា ដើម្បីធ្វើឱ្យផ្នែកដែលមានអាទិភាពខ្ពស់បំផុតនៃផែនការជាតិអាចដំណើរការបាន។

រាជរដ្ឋាភិបាលមានភារកិច្ចក្នុងការអនុម័តផែនការជាតិទាំងមូល និងកំណត់ថវិកាដែលចាំបាច់សំរាប់កិច្ចដំណើរការនៃផែនការជាតិ។

# ជំពូក ៥

# ការអនុវត្តន៍គំរោង

# អាទិភាពនានាក្នុងកិច្ចសហប្រតិបត្តិការ

# តំបន់ និងអន្តរជាតិ

# ជំពូក V

# ការអនុវត្តន៍គំរោងអាទិភាពនានា ក្នុងកិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិ

## ១. គំរោងលេខ : AD/CMB/01/F14

**ឈ្មោះគំរោង :** ការពង្រឹងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងកម្មវិធីត្រួតពិនិត្យគ្រឿងញៀនជាតិ

**ស្ថាប័នអនុវត្ត :** ការិយាល័យអង្គការសហប្រជាជាតិសំរាប់ការត្រួតពិនិត្យគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC)

**រយៈពេល :** ៥១ ខែ ចាប់ផ្តើមពី ខែមេសា ឆ្នាំ២០០១ ដល់ខែមិថុនា ឆ្នាំ២០០៥

**ថវិកាសរុប :** ២.១០១.៧៣៦ដុល្លារ ( ថវិកា ៤០០,០០០ ដុល្លារទៀតកំពុងត្រូវបានស្វែងរក)

**គោលដៅ :**

បង្កើនសមត្ថភាពថ្នាក់ជាតិសំរាប់ការអភិវឌ្ឍន៏ ការសំរបសំរួល និងការអនុវត្តន៏ប្រកបដោយជោគជ័យនូវកម្មវិធីត្រួតពិនិត្យគ្រឿងញៀនឱ្យមាននិរន្តរភាព និងមានភាពទូលំទូលាយនៅកម្ពុជា ។ ជួយពង្រឹងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ឱ្យមាននិរន្តរភាព និងជាស្ថាប័នដ៏មានប្រសិទ្ធិភាពឈរលើគោលការណ៏វិជ្ជាជីវៈនិងម្ចាស់ការ (Integrity) ហើយនឹងត្រូវបានដើរតួជាស្ថាប័នកណ្តាលសំរាប់កសាងផែនការ ធ្វើការសំរបសំរួល ប្រតិបត្តិការនយោបាយត្រួតពិនិត្យគ្រឿងញៀនជាតិរបស់រាជរដ្ឋាភិបាល និងជាតំណាងសមត្ថកិច្ចរបស់ប្រទេសក្នុងកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ និងតំបន់។

**លទ្ធផលៈ**

លទ្ធផល ១: ក្រុមគំរោងត្រូវបានជ្រើសរើស និងដំណើរការ។

លទ្ធផល ២: ពង្រឹងរចនាសម្ព័ន្ធតួនាទី របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងនីតិវិធីប្រតិបត្តិការ និងការចាត់ចែងជាមូលដ្ឋាន។

លទ្ធផល ៣: ពង្រឹងរចនាសម្ព័ន្ធ តួនាទី ភារកិច្ច ថ្នាក់ក្រោមរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ។

លទ្ធផល ៤: លក្ខណៈសម្បត្តិរបស់បុគ្គលិកអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវបានបង្កើនសំរាប់ធានាបាននូវការបំពេញភារកិច្ចជាមូលដ្ឋានទាំងឡាយ ។

លទ្ធផល ៥ : ពង្រឹងយន្តការសំរបសំរួលជាមូលដ្ឋានជាមួយស្ថាប័នដៃគូ និងអង្គការអន្តរជាតិនានា ។

លទ្ធផល ៦ : ផែនការសកម្មភាពជាមូលដ្ឋាន សំរាប់អាទិភាពទាំងឡាយត្រូវបានពង្រឹង និងការចាប់ផ្តើមអនុវត្ត ។

លទ្ធផល៧ : ប្រព័ន្ធពតិមានជាមូលដ្ឋាននៃការអនុវត្តន៍ច្បាប់ និងការកាត់បន្ថយការផ្គត់ផ្គង់ ត្រូវបានដាក់ឱ្យដំណើរការនៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងនៅខេត្តអាទិភាពមួយចំនួន ។ ( គំរោង...C46 )

លទ្ធផល ៨ : មូលដ្ឋាននៃប្រព័ន្ធវិភាគពតិមាន និងប្រមូលទិន្នន័យកាត់បន្ថយតំរូវការ នៅលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងថ្នាក់ជាតិ ត្រូវបានពង្រឹង និងដំណើរការ ។ ( គំរោង...F97 )

លទ្ធផល ៩ : សកម្មភាពគំរោងដំណាក់កាលទី១ ត្រូវបានត្រួតពិនិត្យវាយតំលៃឡើងវិញ ហើយផែនការគំរោងលំអិតសំរាប់ការអភិវឌ្ឍន៍ដំណាក់កាលទី២ ត្រូវបានអភិវឌ្ឍ ។

លទ្ធផល១០ : ប្រព័ន្ធនិងសកម្មភាពប្រតិបត្តិការរបស់ អ.ជ.ប.គ.ញ ត្រូវបានពង្រឹងដើម្បីឆ្លើយតបទៅនឹងតំរូវការជាតិ និងអន្តរជាតិ ។

លទ្ធផល១១ : ប្រព័ន្ធនៃការបណ្តុះបណ្តាលជំនាញ និងឯកទេសសំរាប់បុគ្គលិក របស់អគ្គលេខាធិការដ្ឋាន និងដៃគូសហប្រតិបត្តិការសំខាន់នានាត្រូវបានដំណើរការ ។

លទ្ធផល១២ : ប្រព័ន្ធសំរាប់ និរន្តរភាពថវិកា និងការគ្រប់គ្រងបុគ្គលិកត្រូវបានពង្រឹង ។

លទ្ធផល១៣ : ផែនការត្រួតពិនិត្យគ្រឿងញៀនថ្នាក់ជាតិមួយត្រូវបានបង្កើត និងដាក់ឱ្យដំណើរការនៅពេលខាងមុខ ។

## ២. គំរោងលេខ AD/RAS/ 99/D91

**ឈ្មោះគំរោង :** ការអភិវឌ្ឍន៍កិច្ចសហប្រតិបត្តិការអនុវត្តន៍ច្បាប់ឆ្លងកាត់ព្រំដែននៅអាស៊ីខាងកើត

**ស្ថាប័នអនុវត្ត :** ការិយាល័យអង្គការសហប្រជាជាតិ សំរាប់ការត្រួតពិនិត្យគ្រឿងញៀន និងឧក្រិដ្ឋកម្ម ( UNODC )

**រយះពេល :** ៤ឆ្នាំ ចាប់ផ្តើមពីខែកក្កដា ឆ្នាំ ១៩៩៩ ដល់ខែធ្នូ ឆ្នាំ២០០៣ បន្តរហូតដល់ ៣១ ធ្នូ ២០០៥

**ថវិកាសរុប :** ២.៨០៨.៩៦៨ ដុល្លារ ( សំរាប់បណ្តាប្រទេសជាសមាជិក MOU ទាំង៦ )

**គោលដៅ :**

ធ្វើអោយប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែន និងការអនុវត្តន៍ច្បាប់គ្រឿងញៀន នៅតាមចំណុចគោលដៅ និងតំបន់ព្រំដែនអាទិភាពនានានៃតំបន់អាស៊ីអាគ្នេយ៍តាមរយះ

១. ពង្រឹង និងលើកកំពស់កិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែន តាមរយៈការបង្កើតរចនាសម្ព័ន្ធទំនាក់ទំនងដើម្បីកិច្ចសហប្រតិបត្តិការជាទៀងទាត់ និងជាបន្តបន្ទាប់ ។

២. បង្កើនសមត្ថភាពមន្ត្រីអនុវត្តច្បាប់នៅតំបន់ឆ្លងកាត់ព្រំដែន និង/ឬចំណុចត្រួតពិនិត្យនៅក្នុងផ្ទៃប្រទេសដើម្បី :

ក. ចេះប៉ាន់ស្មាន និងវាយតំលៃអំពីការប្រឈមមុខនឹងគ្រោះថ្នាក់ ការពិនិត្យជាទូទៅ និងការប្រើ

បច្ចេកទេសពិសេសក្នុងការត្រួតពិនិត្យ យានយន្ត នាវា-ទូក និងអ្នកថ្មើរជើង ។

ខ. ស្វែងរកចាប់គ្រឿងញៀនខុសច្បាប់ និងការដឹកញ្ជូនដោយសង្ស័យនូវសាច់ប្រាក់ និងសារធាតុគីមីផ្សំដែលលាក់ក្នុងទំនិញ យានយន្ត នាវា-ទូក និងអ្នកថ្មើរជើង ។

៣. រៀបចំបណ្តុះបណ្តាលសមត្ថភាពមន្ត្រីអនុវត្តច្បាប់ អំពីអត្តសញ្ញាណ និងការវិភាគនៃគ្រឿងញៀន និងសារធាតុគីមីផ្សំ ។

**លទ្ធផល :**

<u>លទ្ធផល ១ :</u> រចនាសម្ព័ន្ធទំនាក់ទំនងឆ្លងកាត់ព្រំដែន នៃមន្ត្រីអនុវត្តន៍ច្បាប់ត្រូវបានបង្កើត និងដំណើរការនៅមូលដ្ឋានស្មុគ្រស្មាញដែលត្រូវបានជ្រើសរើស ។

<u>លទ្ធផល ២ :</u> កម្មវិធីបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់គ្រឿងញៀនដោយយកកុំព្យូទ័រជាមូលដ្ឋាន(CBT) ត្រូវបានបង្កើតបន្ថែមរហូតដល់ចំណុចព្រំដែន ។

<u>លទ្ធផល ៣ :</u> មន្ត្រីអនុវត្តច្បាប់នៅតាមចំណុចគោលដៅត្រូវបានបណ្តុះបណ្តាលការងារបច្ចេកទេស ។

<u>លទ្ធផល ៤ :</u> ប្រព័ន្ធសហប្រតិបត្តិការត្រូវបានបង្កើត ។

<u>លទ្ធផល ៥ :</u> មេរៀនពិសោធន៍ដែលបានមកពីការអនុវត្តន៍គំរោងត្រូវបានទទួលស្គាល់ កត់ត្រា និងផ្សព្វផ្សាយ ។

<u>**បញ្ជាក់:**</u> ការិយាល័យទំនាក់ទំនងច្រកទ្វារព្រំដែនចំនួន ១៦ការិយាល័យនឹងត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៤ ហើយចំនួនចាប់ពី ៤ ទៅ ១០ ការិយាល័យទៀតនឹងត្រូវបង្កើតឡើងនៅឆ្នាំ២០០៥ ក្នុងចំណោមបណ្តាប្រទេសជាសមាជិក MOU ដែលនៅតាមដងទន្លេមេគង្គ ។

## ៣. <u>**គំរោងលេខ** AD/RAS/ 01/ F34</u>

**ឈ្មោះគំរោង :** ការត្រួតពិនិត្យសារធាតុគីមីផ្សំនៅអាស៊ីខាងកើត ។

**ស្ថាប័នអនុវត្ត :** ការិយាល័យអង្គការសហប្រជាជាតិ សំរាប់ការត្រួតពិនិត្យគ្រឿងញៀន និង ឧក្រិដ្ឋកម្ម (UNODC)

**រយះពេល :** ៤ឆ្នាំ ចាប់ផ្តើមពីខែវិច្ឆិកា ឆ្នាំ២០០១ ដល់ខែតុលា ឆ្នាំ២០០៥

**ថវិកាសរុប :** ១.៧៩៣.៧០០ដុល្លារ (សំរាប់បណ្តាប្រទេសជាសមាជិក MOU ទាំង៦រួមទាំង ហ្វីលីពីន និងឥណ្ឌូនេស៊ី)

**គោលដៅ :**

ក) ពង្រឹងការត្រួតពិនិត្យជំនួញស្របច្បាប់ និងការបង្ក្រាបការចរាចរខុសច្បាប់នៅក្នុងបណ្តាប្រទេសជាសមាជិកMOU ។

ខ) ពង្រឹងសមត្ថភាពបណ្តាប្រទេសដែលជាប់ព្រំដែនជាមួយបណ្តាប្រទេសជាសមាជិក MOU ដើម្បីទប់ស្កាត់ការចរាចរ និងការបង្វែរសារធាតុគីមី នៅក្នុងស្រុក និងនៅក្នុងតំបន់ ។

គ) លើកកំពស់កិច្ចសហប្រតិបត្តិការក្នុងចំណោមប្រទេសអាស៊ីអាគ្នេយ៍ និងអាស៊ីខាងកើត ដើម្បីបង្ការការបង្វែរ និងការចរាចរសារធាតុគីមីផ្សំដោយកន្លែងផលិតគ្រឿងញៀនលួចលាក់ ។

**លទ្ធផល :**

ក) សេចក្តីរាយការណ៍ពីសកម្មភាពហាមឃាត់សារធាតុគីមីផ្សំ នៅតំបន់ព្រំដែនរួម នៃប្រទេសចិន ភូមា ថៃ និងឡាវ ដោយផ្តោតទៅលើតំបន់ដងទន្លេមេគង្គ និងប្រទេសចិនភាគខាងត្បូងត្រូវបានបញ្ចប់និងដាក់ជូនទៅអាជ្ញាធរ-គ្រឿងញៀនជាតិនៃបណ្តាប្រទេសទាំងនេះ ។

ខ) ផែនការសកម្មភាពជាតិ ត្រូវបានរៀបចំដោយប្រទេសនីមួយៗដែលជាសមាជិក MOU ។

គ) មន្ត្រីសំខាន់នៅក្នុងស្ថាប័នត្រួតពិនិត្យរបស់ប្រទេសហ្វីលីពីន និងឥណ្ឌូនេស៊ី ត្រូវបានទទួលចំណេះដឹងគ្រប់គ្រាន់សំរាប់ការបង្ការការបង្វែរសារធាតុគីមីផ្សំពីជំនួញស្របច្បាប់ទៅទីផ្សារខុសច្បាប់ ។

ឃ) មន្ត្រីសំខាន់ៗ និងអ្នករៀបចំគោលនយោបាយរបស់ឧស្សាហកម្មគីមីនៅប្រទេសហ្វីលីពីន ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី ត្រូវបានផ្តល់ចំណេះដឹងស្តីពីការត្រួតពិនិត្យសារធាតុគីមីផ្សំ ។

ង) ប្រព័ន្ធថ្នាក់ជាតិបានត្រូវបានរៀបចំនៅក្នុងប្រទេសហ្វីលីពីននិងឥណ្ឌូនេស៊ីដើម្បីប្រមូលផ្តុំនិងចែករំលែកពតិមានក្នុងចំណោមស្ថាប័នត្រួតពិនិត្យ និងស្ថាប័នអនុវត្តច្បាប់ ។

ច) អ្នកឧទ្ទេសនាមនៅប្រទេសហ្វីលីពីននិងឥណ្ឌូនេស៊ីបានទទួលការបណ្តុះបណ្តាលអំពីចំណេះដឹងជាមូលដ្ឋានស្តីពីសារធាតុគីមីផ្សំ និងការហាមឃាត់និងការស៊ើបអង្កេតនៃការបង្វែរនិងការចរាចរសារធាតុគីមីផ្សំ ។

ឆ) ផែនការតំបន់ត្រូវបានរៀបចំឡើងសំរាប់កិច្ចសហប្រតិបត្តិការក្នុងចំណោមប្រទេសនៅអាស៊ីខាងកើត និងប្រទេសនៅអាស៊ីភាគអាគ្នេយ៍ ។

## ៤. <u>គំរោងលេខ AD/RAS/ 00/ F73</u>

**ឈ្មោះគំរោង :** យន្តការសហប្រតិបត្តិការតំបន់ដើម្បីតាមដាននិងអនុវត្តផែនការសកម្មភាព ACCORD (Asean China Coorperative Operation in Response to Dangerous Drugs)

**ស្ថាប័នអនុវត្ត :** ការិយាល័យអង្គការសហប្រជាជាតិ សំរាប់ការត្រួតពិនិត្យគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC)

**រយៈពេល :** ៣ឆ្នាំ ចាប់ផ្តើមពីខែមេសា ឆ្នាំ២០០២

**ថវិកាសរុប :** ១.៣៣៣.៦០០ដុល្លារអាមេរិក ( សំរាប់ប្រទេសជាសមាជិកអាស៊ាន បូកចិន )

**គោលដៅ :**

គោលដៅបន្ទាន់គឺបង្កើតនិងលើកកំពស់យន្តការសំរបសំរួលដ៏សមរម្យនិងរស់រវើកមួយដើម្បីជួយសំរួលដល់ដំណើរការអនុវត្តផែនការសកម្មភាព ACCORD ក្នុងចំណោមប្រទេសដែលចូលរួមទាំងឡាយ ក្នុងនោះរួមមានការតាមដានការរីកចំរើន ការផ្លាស់ប្តូរពតិមាន និងការវិភាគស៊ីជំរៅស្តីពីនិន្នាការត្រួតពិនិត្យគ្រឿងញៀននៅក្នុងតំបន់ និងជួយសំរបសំរួលយុទ្ធសាស្ត្រត្រួតពិនិត្យគ្រឿងញៀនថ្នាក់ជាតិនៃបណ្តាប្រទេសជាដៃគូទាំងដប់មួយ អោយមានភាពរឹតតែសមស្របតាមផែនការសកម្មភាពបន្ថែមទៀត ។

**លទ្ធផល :**

<u>លទ្ធផល ១ :</u> ប្រពន្ធ័ប្រមូលផ្តុំ និងរៀបចំពតិមាននឹងត្រូវបានបង្កើត ។

<u>លទ្ធផល ២ :</u> ក្រុមការងារ ACCORD នានា ព្រមទាំងលក្ខ័ណ្ឌស្តីពីតួនាទីនិងភារកិច្ចជាក់លាក់ត្រូវបានបង្កើត និងត្រូវបានអនុវត្តយ៉ាងសកម្មនៅបណ្តាប្រទេសសមាជិកទាំងអស់ ។

<u>លទ្ធផល ៣ :</u> យន្តការតាមដាន ធ្វើរបាយការណ៍ ចងក្រងឯកសារ និងផ្សព្វផ្សាយពតិមានដ៏មានប្រសិទ្ធិភាពមួយ សំរាប់សំរបសំរួលផែនការសកម្មភាព ACCORD ត្រូវបានដំណើរការ ។

<u>លទ្ធផល ៤ :</u> បង្កើនសមត្ថភាពជាតិនិងអនុតំបន់សំរាប់កិច្ចសហប្រតិបត្តិការ ការសំរបសំរួល ការចែក-ចាយពតិមាន ការរៀបចំបណ្តាញការងារ ការចរចា និងការគាំទ្រគ្នាទៅវិញទៅមកក្នុងចំណោមបណ្តាស្ថាប័នត្រួតពិនិត្យគ្រឿងញៀនថ្នាក់តំបន់និងថ្នាក់ជាតិ ។

## ៥. <u>**គំរោងលេខ** F97 : **ការប្រមូលទិន្នន័យ** ATS(Amphetamine Type Stimulant)</u>

**ឈ្មោះគំរោង :** ការអនុវត្តន៏សកម្មភាពប្រឆាំងការប្រើបំពាន ATS: ការធ្វើអោយប្រសើរនូវប្រព័ន្ធប្រមូលពតិមាន និងទិន្នន័យ ATS ។

**ស្ថាប័នអនុវត្ត :** ការិយាល័យអង្គការសហប្រជាជាតិ សំរាប់ការត្រួតពិនិត្យគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC)

**រយះពេល :** ២ ឆ្នាំ ចាប់ផ្តើមពីខែមករា ឆ្នាំ ២០០២ ដល់ខែធ្នូ ឆ្នាំ២០០៤

**ថវិកាសរុប :** ៤០០.០០០ ដុល្លារអាមេរិក ( សំរាប់បណ្តាប្រទេសជាសមាជិក MOU ទាំង៦ )

**គោលដៅ :**

ស្ថាប័ននានានៃប្រទេសដែលបានជ្រើសរើសនៅក្នុងតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិកនឹងអនុម័តលើវិធានការដ៏មានប្រសិទ្ធិភាពសំរាប់ការបង្ការ និងការកាត់បន្ថយការប្រើបំពាន ATS ។ ហេដ្ឋារចនាសម្ព័ន្ធត្រូវបានបង្កើតសំរាប់ការយោគយល់គ្នាអំពីគំរូ ATS នៅក្នុងតំបន់ និងសំរាប់ការផ្លាស់ប្តូរពតិមានដែលទាក់ទងទៅនឹងការត្រួតពិនិត្យនិងការបង្ការការប្រើបំពាន ATS ។

**លទ្ធផល :**

<u>លទ្ធផល ១ :</u> ត្រួតពិនិត្យឡើងវិញអំពីការងារបង្ការទប់ស្កាត់ការប្រើបំពាន ATS ក្នុងគំរោងតំបន់រួម បញ្ចូលទាំងការបង្ការ ការព្យាបាល និងបទពិសោធន៍ល្អៗទាំងឡាយ ។

<u>លទ្ធផល ២ :</u> អាទិភាពូបនីយកម្មលើការងារប្រមូលទិន្នន័យថ្នាក់តំបន់និងថ្នាក់ជាតិ និងគំរូវការផ្លាស់ប្តូរពតិមានស្តីពីការបង្ការទប់ស្កាត់ការប្រើបំពាន ATS ។

<u>លទ្ធផល ៣ :</u> គំរូរបាយការណ៍ទិន្នន័យ ATS ត្រូវបានរៀបចំឱ្យមានស្តង់ដាថ្នាក់តំបន់ ។

<u>លទ្ធផល ៤ :</u> មជ្ឈមណ្ឌលពតិមានថ្នាក់កណ្តាលប្រចាំតំបន់អំពី ATS ត្រូវបានបង្កើត និងដំណើរការ ។

## ៦. <u>គំរោងលេខ AD/RAS/ 02/ G22</u>

**ឈ្មោះគំរោង :** កាត់បន្ថយភាពគ្រោះថ្នាក់នៃមេរោគអេដស៍ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន

**ស្ថាប័នអនុវត្ត :** ការិយាល័យអង្គការសហប្រជាជាតិ សំរាប់ការត្រួតពិនិត្យគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC)

**រយៈពេល :** ០២ ឆ្នាំ ចាប់ផ្តើមពីខែមេសា ឆ្នាំ២០០២ ដល់ខែមិនា ឆ្នាំ២០០៤

**ថវិកាសរុប :** ១,៤ លានដុល្លារអាមេរិក ( សំរាប់បណ្តាប្រទេសជាសមាជិក MOU ទាំង៦ )

**គោលដៅ :**

ស្ថាប័ននានានៃប្រទេសដែលបានជ្រើសរើសនៅក្នុងតំបន់អាស៊ីខាងកើតនិងប៉ាស៊ីហ្វិកនឹងអនុម័តនូវវិធានការដ៏មានប្រសិទ្ធិភាពសំរាប់ការកាត់បន្ថយការប្រើបំពានគ្រឿងញៀននិងដើម្បីពង្រឹងការឆ្លើយតបរបស់រដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងតំបន់អាស៊ីខាងកើត ដើម្បីទប់ស្កាត់ការចំលងមេរោគអេដស៍ដែលទាក់ទងទៅនឹងការប្រើបំពានគ្រឿងញៀន ។

**លទ្ធផល :**

<u>លទ្ធផល ១ :</u> បញ្ចប់ការត្រួតពិនិត្យឡើងវិញជាដំបូងពីលក្ខណៈតំបន់ភូមិសាស្ត្រ និងសមត្ថភាពរបស់ស្ថាប័នសំខាន់ៗ ។ យន្តការអន្តរស្ថាប័ននានាត្រូវបានបង្កើតនិងដំណើរការ ។ សកម្មភាពនានាស្តីពីការបង្ការទប់ស្កាត់មេរោគអេដស៍និងការថែទាំអ្នកជម្ងឺអេដស៍ត្រូវបានសំរបសំរួលបញ្ចូលទៅក្នុងយុទ្ធសាស្ត្រនៃការព្យាបាល និងការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

<u>លទ្ធផល ២ :</u> យុទ្ធសាស្ត្រ និងសកម្មភាពនានាស្តីពីការបង្ការទប់ស្កាត់មេរោគអេដស៍ដែលពាក់ព័ន្ធនឹងការប្រើបំពានគ្រឿងញៀនត្រូវបានពង្រីកបន្ថែម ។ បទពិសោធន៍ល្អៗនៅក្នុងតំបន់ត្រូវបានកត់សំគាល់និងយកមកប្រើប្រាស់ ។

## ៧. ឈ្មោះគំរោង : កម្មវិធីលើកកំពស់កិច្ចសហប្រតិបត្តិការបច្ចេកទេសតំបន់

**ស្ថាប័នអនុវត្ត :** ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន JICA

**រយៈពេល :** ៣ឆ្នាំ ចាប់ផ្តើមពីខែមិថុនា ឆ្នាំ២០០២

**ថវិកាសរុប :**

**គោលដៅ :**

ការវិភាគគ្រឿងញៀនច្បាស់លាស់ (អំពីបរិមាណ គុណភាព ភាពសុទ្ធ និងការចងក្រងឯកសារ) នឹងត្រូវបាន អនុវត្តដើម្បីពង្រឹងសមត្ថភាពអនុវត្តច្បាប់នៅក្នុងបណ្តាប្រទេស កម្ពុជា ឡាវ ភូមា វៀតណាម ថៃ (CLMVT)។

**លទ្ធផល :**

<u>លទ្ធផល ១ :</u> មន្ត្រីសំខាន់នៃមន្ទីរពិសោធន៍នានានៅតាមបណ្តាប្រទេស កម្ពុជា ឡាវ ភូមា វៀតណាម ថៃ នឹងទទួលបាននូវចំណេះដឹង និងបច្ចេកទេសស្តីពីការវិភាគលើបរិមាណ និងគុណភាព។

<u>លទ្ធផល ២ :</u> អ្នកវិភាគគ្រឿងញៀនមួយចំនួននៃបណ្តាប្រទេស កម្ពុជា ឡាវ ភូមា វៀតណាម ថៃ នឹងទទួលបានចំណេះដឹងនិងបច្ចេកទេសស្តីពីការវិភាគភាពសុទ្ធ។

## ៨. គំរោងលេខ CMB/03/ 006/A/RC/34

**ឈ្មោះគំរោង :** ការវាយតំលៃទូទាំងប្រទេសអំពីអាកប្បកិរិយាដែលមានគ្រោះថ្នាក់និងវិធានការអន្តរាគមន៍របស់ស្ថាប័នក្នុងចំណោមក្រុមប្រជាជនគោលដៅ។

**ស្ថាប័នអនុវត្ត :** ការិយាល័យអង្គការសហប្រជាជាតិ សំរាប់ការត្រួតពិនិត្យគ្រឿងញៀន និង ឧក្រិដ្ឋកម្ម UNODC

**រយៈពេល :** ១,៥ឆ្នាំ ចាប់ផ្តើមពីខែធ្នូ ឆ្នាំ២០០២

**ថវិកាសរុប :** ៦៥.០០០ដុល្លារអាមេរិក (ជំនួយ US CDC តាមរយៈ UNAIDS)

**គោលដៅ :**

ពង្រឹងសមត្ថភាពជាតិសំរាប់តាមដាន វាយតំលៃ និងស្រាវជ្រាវតាមរយៈការរកឃើញកត្តាដ៏គ្រោះថ្នាក់នានាដែលលេចចេញឡើង និងប្រជាជនដែលប្រឈមមុខនឹងការចំលងជំងឺអេដស៍តាមរយៈការប្រើបំពានគ្រឿងញៀន និងដើម្បីអភិវឌ្ឍនូវបណ្តាអន្តរាគមន៍ដែលពឹងផ្អែកលើភស្តុតាងជាក់លាក់ និងដែលយកសហគមន៍ធ្វើជាមូលដ្ឋាន។

**លទ្ធផល :**

<u>លទ្ធផល ១ :</u> ពណ៌នាដោយមានការវិភាគទៅលើទ្រង់ទ្រាយ និងកត្តាកំណត់នៃអាកប្បកិរិយាគ្រោះថ្នាក់ក្នុងចំណោមក្រុមប្រជាជនគោលដៅ(ឧទាហរណ៍: ស្ត្រីលក់ស្រាបៀ, បុគ្គលិកកាស៊ីណូ, កម្មកររោងចក្រកាត់ដេរ, និងដៃគូទាំងអស់នៃក្រុមងាយរងគ្រោះខាងលើនេះ)។

លទ្ធផល ២ : កំណត់បានពីរចនាសម្ព័ន្ធសំរាប់ធ្វើអន្តរាគមន៍ ។

លទ្ធផល ៣ : យល់ដឹងច្បាស់លាស់ពីចំណងទាក់ទងរវាងការប្រើប្រាស់គ្រឿងញៀននិងការចំលងមេរោគអេដស៍ក្នុងចំណោមក្រុមប្រជាជនគោលដៅ ។

លទ្ធផល ៤ : រៀបចំគំរោងអន្តរាគមន៍ចំពោះក្រុមប្រជាជនគោលដៅនីមួយៗ ។

លទ្ធផល ៥ : ធានាបាននូវការចូលរួម និងភាពត្រៀមបំរុងជាស្រេចពីដៃគូផ្សេងៗដើម្បីអន្តរាគមន៍ ។

## ៩. គំរោងកសាងសមត្ថភាពជាតិសំរាប់ធ្វើការវាយតំលៃរហ័សអំពីបញ្ហាគ្រឿងញៀន និងសំរាប់រៀបចំអន្តរាគមន៍សំរាប់ក្រុមប្រជាជនគោលដៅ

**ស្ថាប័នអនុវត្ត :** អង្គការសុខភាពពិភពលោក (WHO)

**រយៈពេល :** ១ឆ្នាំ ចាប់ផ្តើមពីខែមករា ឆ្នាំ២០០៣ ដល់ខែធ្នូ ឆ្នាំ២០០៣

**ថវិកាសរុប :** ៦៥.000 ដុល្លារអាមេរិក ( ជំនួយ US CDC តាមរយៈ UNAIDS )

**គោលដៅ :** កសាងសមត្ថភាពជាតិសំរាប់ធ្វើការវាយតំលៃរហ័សអំពីបញ្ហាគ្រឿងញៀន និងអេដស៍

**លទ្ធផល :**

លទ្ធផល ១ : សិក្សាអំពីចរិតនិងវិសាលភាពនៃគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀនបច្ចុប្បន្ន ក្នុងនោះរាប់បញ្ចូលទាំងបណ្តាញទំនាក់ទំនងរវាងការប្រើប្រាស់និងការចែកចាយគ្រឿងញៀន( ដោយផ្អែកលើទស្សនៈអ្នកប្រើប្រាស់គ្រឿងញៀន) ។

លទ្ធផល ២ : ស្វែងយល់អំពីកត្តាដែលជះឥទ្ធិពលទៅលើចរិតគ្រោះថ្នាក់ដែលពាក់ពន្ធ័ការរួមភេទ និងគ្រឿងញៀន ព្រមទាំងវិធានការ ការពារនានាដែលពាក់ព័ន្ធនឹងគ្រោះថ្នាក់នៃមេរោគ HIV / AIDS ក៏ដូចជាស្វែងយល់អំពីសេវាកម្មនានាដែលអាចឬមិនអាចប្រើប្រាស់បានសំរាប់អ្នកប្រើប្រាស់គ្រឿងញៀន ។

លទ្ធផល ៣ : ស្វែងយល់អំពីការងាយស្រួល និងការលំបាកក្នុងការណែនាំអន្តរាគមន៍ ដើម្បីជួយទប់ស្កាត់ការរីករាលដាលនៃជំងឺអេដស៍ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀន ។

លទ្ធផល ៤ : ផ្តល់អនុសាសន៍នានាសំរាប់ការចាប់ផ្តើម ការពង្រីក និងនិរន្តរភាពនៃអន្តរាគមន៍នានា ដែលរៀបចំឡើងសំរាប់ជួយអ្នកប្រើប្រាស់គ្រឿងញៀន ជាពិសេសដើម្បីទប់ស្កាត់គ្រោះថ្នាក់នៃការឆ្លងមេរោគហ៊ីវ/អេដស៍ ។

# ជំពូក ៦

# ការតាមដាន និងការវាយតំលៃ

# ជំពូក VI
# ការតាមដាន និងការវាយតំលៃ

## ១. យន្តការ និងបែបបទសំរាប់តាមដាន និងវាយតំលៃ

តួនាទីតាមដាននឹងត្រូវធ្វើឡើងដោយអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដែលមាននាយកដ្ឋានផែនការ និងបណ្តុះបណ្តាលជាអ្នកសំរបសំរួល។ ចាំបាច់ត្រូវមានការរៀបចំកិច្ចប្រជុំរវាងមន្ត្រីសំខាន់ៗនៃ អ.ជ.ប.គ.ញ និងអ្នកជំនាញការក្នុងស្រុក ដើម្បីរៀបចំឱ្យមានការឯកភាពគ្នាទៅលើបញ្ជីសន្ទស្សន៍លទ្ធផលដែលនឹងត្រូវយកទៅប្រើប្រាស់សំរាប់ការតាមដាន និងផ្ទៀងផ្ទាត់ដំណើរការអនុវត្តន៍ផែនការជាតិ។

ផ្អែកលើផែនការលំអិតប្រចាំឆ្នាំ ព្រមទាំងបញ្ជីសន្ទស្សន៍លទ្ធផលគ្រប់គ្រាន់ហើយនោះ អង្គភាពដែលទទួលខុសត្រូវសំរាប់ការងារនេះ អាចមានលទ្ធភាពក្នុងការតាមដាន និងត្រួតពិនិត្យនូវការអនុវត្តន៍។ របាយការណ៍ជាខ្សែសង្វាក់មួយដើម្បីគូសបញ្ជាក់អោយដឹងថាអ្វីបានដំណើរការនិងអ្វីមិនបានដំណើរការទាន់ពេលវេលានឹងជួយជំរុញល្បឿនព្រមទាំងតំរង់ទិសដៅក្នុងការអនុវត្តន៍នៃផែនការជាតិ។ ការបណ្តុះបណ្តាលបន្ថែមសំរាប់មន្ត្រីទាំងឡាយណាដែលទទួលរ៉ាប់រងក្នុងការអនុវត្តន៍ការងារនេះគឺជាតំរូវការចាំបាច់។

## ២. កាលវិភាគសំរាប់ការវាយតំលៃ

ការវាយតំលៃលទ្ធផលអនុវត្តនៅពាក់កណ្តាលគំរោងផែនការជាតិនឹងត្រូវធ្វើឡើងនៅពាក់កណ្តាលឆ្នាំ២០០៧ ហើយការវាយតំលៃនៅពេលបញ្ចប់គំរោងក៏នឹងត្រូវបានព្រាងទុកផងដែរនៅឆ្នាំ២០១០ ដោយអ្នកជំនាញការផ្នែកវាយតំលៃដែលជ្រើសរើសដោយអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងមានការជួយគាំទ្រពី UNODC ។

ការវាយតំលៃទាំងពីរខាងលើនេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដោយមានការគាំទ្រពី UNODC នឹងបង្កើតតារាងលក្ខ័ណ្ឌការងារទូលំទូលាយនិងច្បាស់លាស់មួយ។ អ្នកវាយតំលៃនឹងធ្វើសេចក្តីព្រាងរបាយការណ៍អំពីការវាយតំលៃដែលរួមបញ្ចូលនូវអនុសាសន៍គន្លឹះនានា ដើម្បីដាក់ជូនទៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ពិនិត្យនិងសំរេច។

អនុសាសន៍សមស្របទាំងឡាយ ដែលបានមកពីការវាយតំលៃទាំងពីរនឹងត្រូវបានអនុវត្តយ៉ាងហ្មឹងម៉ាត់ទៅតាមពេលវេលាដែលបានកំណត់ ហើយនឹងត្រូវបានប្រើជាគំនិតគន្លឹះសំខាន់ក្នុងការបង្កើតផែនការជាតិសំរាប់គំរោងបន្តនៃកម្មវិធីត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា។

## ៣. ការធ្វើវិសោធនកម្មផែនការជាតិ

ផែនការជាតិបច្ចុប្បន្នអាចនឹងត្រូវបានកែសំរួលដោយកត្តាជាច្រើនដូចខាងក្រោម:

ក/ អនុសាសន៍ទាំងឡាយ ដែលបានមកពីការវាយតំលៃពាក់កណ្តាលគំរោងនាឆ្នាំ២០០៧

ខ/ កង្វះថវិកាចាំបាច់ សំរាប់អនុវត្តផែនការជាតិទាំងមូល

គ/ ស្ថានភាពធ្ងន់ធ្ងរនៃការប្រើបំពានគ្រឿងញៀននៅក្នុងប្រទេសកម្ពុជា ដែលនឹងត្រូវបង្ហាញដោយការស្ទាបស្ទង់ថ្នាក់ជាតិ (ក្នុងកំឡុងចុងឆ្នាំ២០០៤ ឬដើមឆ្នាំ២០០៥) ឬការស្ទាបស្ទង់ដូចគ្នា (ពិសេសការស្ទាបស្ទង់របស់ PAF )

ឃ/ការកើនឡើងយ៉ាងខ្លាំងនៃចំនួនអ្នកប្រើបំពានគ្រឿងញៀន ជាពិសេសក្នុងចំណោមយុវជននិងការរីករាលដាលយ៉ាងខ្លាំងនូវមេរោគ ហ៊ីវ/អេដស៍ ក្នុងចំណោមអ្នកប្រើគ្រឿងញៀនចាក់តាមសរសៃ។

ដោយមានគាំទ្រពីការិយាល័យ UNODC អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងដំណើរការកែសំរួលផែនការដើម្បីធានាថាកិច្ចការនេះនឹងត្រូវបានបំពេញយ៉ាងត្រឹមត្រូវ។ ជាមួយគ្នានេះដែរ ការចូលរួមផ្តល់យោបល់យ៉ាងជិតស្និទ្ធពីដៃគូសំខាន់ៗ គឺជាតំរូវការចាំបាច់។

ក្នុងករណីដែលមានបញ្ហាពិសេសសំខាន់ណាមួយនិងមានថវិកាគ្រប់គ្រាន់ ការកែសំរួលផែនការជាតិនេះគួរត្រូវបានធ្វើនៅពាក់កណ្តាលគំរោង។ ការកែសំរួលនេះត្រូវបានធ្វើឡើងដោយគួបផ្សំជាមួយនឹងអនុសាសន៍ទាំងឡាយនៃការវាយតំលៃនៅពាក់កណ្តាលផែនការ។ សិក្ខាសាលាជាផ្លូវការមួយ ដើម្បីអនុម័តលើផែនការជាតិដែលបានកែប្រែនេះនឹងត្រូវបានរៀបចំឡើងដើម្បីធានាថាគ្រប់ដៃគូទាំងអស់នឹងត្រូវបានយល់ដឹងយ៉ាងច្បាស់ពីកំណែផែនការជាតិនេះ។

ជំរើសដែលគួរពិចារណាមួយទៀតជៀសវាងការកែសំរួលបែបនេះ នោះគឺ ការបង្កើតគំរោងដាច់ដោយឡែកមួយដើម្បីដោះស្រាយបញ្ហាថ្មីជាក់លាក់មួយដែលមិនបានចែងក្នុងផែនការជាតិនេះ។ គំរោងដាច់ដោយឡែកមួយចំនួនឬគំនិតផ្តើមផ្សេងៗអាចត្រូវបានរៀបចំឡើងមុនការវាយតំលៃនៅពាក់កណ្តាលផែនការ។ បញ្ហាទាំងអស់នេះអាចត្រូវបានដាក់បញ្ចូលក្នុងពេលតែមួយទៅក្នុងផែនការជាតិ ដែលបានកែសំរួលបន្ទាប់ពីការវាយតំលៃពាក់កណ្តាលផែនការ (២០០៧) ដោយរៀបចំសិក្ខាសាលាផ្លូវការមួយដើម្បីឯកភាពលើផែនការជាតិដែលបានកែសំរួលរួច។

# តារាងឧបសម្ព័ន្ធ

# គំរោងថវិកាចំណាយប្រមាណសំរាប់ផែនការជាតិ ៥ឆ្នាំ(ឆ្នាំ២០០៥-២០១០)

| សកម្មភាព | អាទិភាពទី១($) | អាទិភាពទី២($) | សរុប($) |
|---|---|---|---|
| **១.ពង្រឹងរចនាសម្ព័ន្ធ អ.ជ.ប.គ.ញ និងស្ថាប័នពាក់ព័ន្ធ** | | | |
| ១.១.ក) ពង្រឹងសមត្ថភាពអគ្គលេខាធិការដ្ឋាន និងក្រសួងជាសមាជិក អ.ជ.ប.គ.ញ | ៦០០,០០០ | | ៦០០,០០០ |
| ១.១.ខ) ពង្រឹងរចនាសម្ព័ន្ធគណៈកម្មការត្រួតពិនិត្យគ្រឿងញៀននានា | ៤០០,០០០ | | ៤០០,០០០ |
| ១.១.គ) ពង្រឹងក្រុមការងារនានា | ១០,០០០ | | ១០,០០០ |
| ១.១.ឃ) បង្កើតបញ្ជីឈ្មោះក្រុមហ៊ុន សហគ្រាស និងគ្រឹះស្ថាននានា | | ១០,០០០ | ១០,០០០ |
| ១.១.ង) ពិនិត្យ និងបង្កើតនូវបទបញ្ញត្តិនិងសេចក្តីណែនាំមួយចំនួន | | ១០,០០០ | ១០,០០០ |
| ១.១.ច) តាមដានទៀងទាត់ចំពោះក្រុមហ៊ុន សហគ្រាស និងគ្រឹះស្ថានមួយចំនួន | | ២០,០០០ | ២០,០០០ |
| ១.២.បង្កើត និងធ្វើឱ្យដំណើរការក្រុមការងារថ្មីៗទៀត | ២០,០០០ | | ២០,០០០ |
| ១.៣.បង្កើតមជ្ឈមណ្ឌលពត៌មានគ្រឿងញៀនមួយ | ៥០,០០០ | | ៥០,០០០ |
| ១.៤.ពង្រឹងកិច្ចសហប្រតិបត្តិការរវាង អ.ជ.ប.គ.ញ ជាមួយនឹងភាគីផ្តល់ជំនួយ | ១០០,០០០ | | ១០០,០០០ |
| **សរុប** | **១.១៨០.០០០** | **៤០.០០០** | **១.២២០.០០០** |
| **២.កាត់បន្ថយតំរូវការគ្រឿងញៀន( ការបង្ការ ការពារ)** | | | |
| ២.១.ក) បង្កើនការយល់ដឹងជាសាធារណៈស្តីពីគ្រឿងញៀន | ១០០,០០០ | | ១០០,០០០ |
| ២.១.ខ) វាយតំលៃអំពីប្រសិទ្ធិភាពនៃសកម្មភាពយល់ដឹងជាសាធារណៈនានា | ៤០,០០០ | | ៤០,០០០ |
| ២.២.ក្រុមយុទ្ធនាការចល័តនឹងធ្វើសកម្មភាពយ៉ាងទៀងទាត់ដើម្បីបង្កើតការយល់ដឹងសាធារណៈ | ២៥០,០០០ | | ២៥០,០០០ |
| ២.៣.ចរចាជាមួយផ្នែកឯកជនផ្សេងៗ | | ២,០០០ | ២,០០០ |
| ២.៤.ក) បញ្ចូលបន្ថែមការអប់រំពីគ្រឿងញៀនទៅក្នុងកម្មវិធីអប់រំគ្រប់កំរិត | ៥០,០០០ | | ៥០,០០០ |
| ២.៤.ខ) ប្រើប្រាស់វិធីសាស្រ្តថ្មីៗដើម្បីទាក់ទាញសាធារណៈជន | | ៦០,០០០ | ៦០,០០០ |
| ២.៥.បង្កើតយន្តការសំរាប់តាមដាន និងវាយតំលៃពីសកម្មភាពបង្ការ | ២០,០០០ | | ២០,០០០ |
| ២.៦.រៀបចំឯកសារនិងចែកចាយពត៌មាន | | ៤០,០០០ | ៤០,០០០ |
| **សរុប** | **៤៦០.០០០** | **១០២.០០០** | ***៥៦២.០០០*** |
| **៣.កាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន** | | | |
| ៣.១.ក) បង្កើតគំរោងអភិវឌ្ឍន៍ដំណាំជំនួសដែលមានប្រសិទ្ធិភាពមួយ | ៥០,០០០ | | ៥០,០០០ |

| | | | |
|---|---|---|---|
| ៣.១.ខ) បង្កើតឯកសារណែនាំពីការអភិវឌ្ឍន៍ដំណាំជំនួស | ៤០,០០០ | | ៤០,០០០ |
| ៣.១.គ) ស្វែងរកទីផ្សារក្នុងស្រុក និងអន្តរជាតិ | | ៤០,០០០ | ៤០,០០០ |
| ៣.១.ឃ) បង្កើតយន្តការការតាមដាន និងការវាយតំលៃ | | ៤០,០០០ | ៤០,០០០ |
| ៣.២.យុទ្ធនាការលប់បំបាត់ដំណាំគ្រឿងញៀន | ៨០,០០០ | | ៨០,០០០ |
| ៣.៣.ដាក់បញ្ចូលច្បាប់គ្រឿងញៀនទៅក្នុងកម្មវិធីការយល់ដឹងសាធារណៈនានា | ៨០,០០០ | | ៨០,០០០ |
| ៣.៤.ក) ស្រាវជ្រាវនៅក្នុងអ៊ីនធឺណិត និងឯកសារផ្សេងទៀតអំពីការដាំដំណាំជំនួស | | ៤,០០០ | ៤,០០០ |
| ៣.៤.ខ) ទស្សនៈកិច្ចសិក្សានៅក្នុងប្រទេសមួយចំនួនអំពីការដាំដំណាំជំនួស | ៦០,០០០ | | ៦០,០០០ |
| **សរុប** | **៣១០.០០០** | **៨៤.០០០** | ***៣៩៤.០០០*** |

**៤.ត្រួតពិនិត្យការធ្វើចរាចរគ្រឿងញៀនខុសច្បាប់**

| | | | |
|---|---|---|---|
| ៤.១.ក) ពង្រឹងកិច្ចសហប្រតិបត្តិការ អ.ជ.ប.គ.ញ ជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ច | ៦០,០០០ | | ៦០,០០០ |
| ៤.១.ខ) បង្កើតទំរង់របាយការណ៍រួម | ១០,០០០ | | ១០,០០០ |
| ៤.២.ក) បន្តការប្រើប្រាស់ការបណ្តុះបណ្តាលតាមកុំព្យូទ័រដើម្បីពង្រឹងសមត្ថភាព មន្ត្រីដែលពាក់ព័ន្ធ | ១០០,០០០ | | ១០០,០០០ |
| ៤.២.ខ) វាយតំលៃអំពីតំរូវការនៃស្ថាប័នអនុវត្តច្បាប់និងនគរបាលប្រឆាំងគ្រឿងញៀន | ១០,០០០ | | ១០,០០០ |
| ៤.២.គ) វាយតំលៃលទ្ធផលនៃការបណ្តុះបណ្តាល | ២០,០០០ | | ២០,០០០ |
| ៤.៣.ពង្រីកប្រព័ន្ធបណ្តុះបណ្តាលតាមកុំព្យូទ័រ ទៅស្ថាប័ននិងខេត្តផ្សេងៗ | ១០០,០០០ | | ១០០,០០០ |
| ៤.៤.ក) ពង្រឹងការិយាល័យទំនាក់ទំនងព្រំដែនបច្ចុប្បន្ន (BLO) | ៦០,០០០ | | ៦០,០០០ |
| ៤.៤.ខ) បង្កើតយន្តការផ្តល់ពតិមានរហ័ស | ៥០,០០០ | | ៥០,០០០ |
| ៤.៥.ពង្រឹងការត្រួតពិនិត្យសារធាតុផ្សំព្រមទាំងសារធាតុប៉ះពាល់សរសៃប្រសាទ ដទៃទៀត | ៥០,០០០ | | ៥០,០០០ |
| ៤.៦.ក) ស្វែងរកថវិកាដើម្បីគាំទ្រការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីមន្ទីរពិសោធន៍ | | ៨,០០០ | ៨,០០០ |
| ៤.៦.ខ) ស្វែងរកថវិកាដើម្បីពង្រឹងមន្ទីរពិសោធន៍បច្ចុប្បន្ន | | ៨,០០០ | ៨,០០០ |
| ៤.៦.គ) UNODC ផ្តល់គំរូគ្រឿងញៀន | | ៤,០០០ | ៤,០០០ |
| ៤.៦.ឃ) បង្កើតមន្ទីរពិសោធន៍ខ្នាតតូច | | ២៥០,០០០ | ២៥០,០០០ |
| ៤.៦.ង) ផ្តល់ឧបករណ៍និងសំភារៈសំរាប់ធ្វើតេស្តនៅតាមបណ្តាខេត្ត | ១០០,០០០ | | ១០០,០០០ |
| ៤.៧.លើកទឹកចិត្តសាធារណៈជនឱ្យចូលរួមរាយការណ៍ពីពតិមានគ្រឿងញៀន | ១០០,០០០ | | ១០០,០០០ |
| ៤.៨.តាមដានការកាត់ក្តីរបស់តុលាការរាល់ករណីដែលបានប្តឹង | ២០,០០០ | | ២០,០០០ |
| ៤.៩.ផ្តល់ឧបករណ៍សំរាប់ធ្វើការស្រាវជ្រាវដល់ស្ថាប័នពាក់ព័ន្ធ | ៥០,០០០ | | ៥០,០០០ |

| | | | |
|---|---|---|---|
| **សរុប** | **៧៣០.០០០** | **២៧០.០០០** | ***១.០០០.០០០*** |

## ៥.នីតិកម្ម និងការអនុវត្តន៍ច្បាប់

| | | | |
|---|---|---|---|
| ៥.១.តាមដានការធ្វើវិសោធនកម្មច្បាប់ពីគ្រឿងញៀន និងការធ្វើសិក្ខាសាលាជាតិ | ៤០,០០០ | | ៤០,០០០ |
| ៥.២.ក) តាមដានការចូលជាសមាជិកក្នុងអនុសញ្ញាអន្តរជាតិទាំងបី | ៤,០០០ | | ៤,០០០ |
| ៥.២.ខ) ធានាឱ្យបាននូវការអនុវត្តន៍តាមអនុសញ្ញាទាំងនោះដោយបណ្តាស្ថាប័នពាក់ព័ន្ធ របស់រាជរដ្ឋាភិបាល | ១០,០០០ | | ១០,០០០ |
| ៥.៣.រៀបចំសិក្ខាសាលាជាមួយក្រុមហ៊ុននានាស្តីអំពីអនុសញ្ញាគ្រឿងញៀនអន្តរជាតិ ទាំងបី | ៤០,០០០ | | ៤០,០០០ |
| ៥.៤.បង្កើតអនុក្រឹត្យផ្សេងៗទៀតដើម្បីពង្រឹងឡើងវិញនូវការអនុវត្តន៍ច្បាប់ គ្រឿងញៀន | | ១០,០០០ | ១០,០០០ |
| ៥.៥.តាមដាននិងធ្វើឱ្យដំណើរការនូវអនុក្រឹត្យ និងប្រកាសពាក់ព័ន្ធទាំងបួនដែលមាន ចែងក្នុងច្បាប់គ្រឿងញៀន | | ២០,០០០ | ២០,០០០ |
| ៥.៦.ពិចារណាអំពីការប្រើប្រាស់ច្បាប់ផ្សេងៗទៀតរបស់កម្ពុជាដើម្បីដោះស្រាយ បញ្ហាឧក្រិដ្ឋកម្មនានា | | ២០,០០០ | ២០,០០០ |
| ៥.៧.ធ្វើបណ្តឹងទៅសាលាឧទ្ធរណ៍នៅក្នុងករណីតុលាការខេត្តក្រុងកាត់ក្តីមិនបាន សមស្រប | ១០,០០០ | | ១០,០០០ |
| **សរុប** | **១០៤.០០០** | **៥០.០០០** | ***១៥៤.០០០*** |

## ៦.ការព្យាបាល និងស្តារនីតិសម្បទា

| | | | |
|---|---|---|---|
| ៦.១.បង្កើតគោលនយោបាយសំរាប់ការព្យាបាល និងស្តារនីតិសម្បទា | ២០,០០០ | | ២០,០០០ |
| ៦.២.ក) បង្កើតមជ្ឈមណ្ឌលមួយសំរាប់ការព្យាបាលនិងស្តារនីតិសម្បទា (ដែលរួមបញ្ចូលទាំងតំលៃប្រតិបត្តិការ) | ៣,០០០,០០០ | | ៣,០០០,០០០ |
| ៦.២.ខ) រៀបចំមជ្ឈមណ្ឌលខាងលើឱ្យទៅជាមន្ទីរពេទ្យរដ្ឋ | | ២.០០០ | ២.០០០ |
| ៦.២.គ) រៀបចំបុគ្គលិកឱ្យបានសមស្របសំរាប់មជ្ឈមណ្ឌល | ២០,០០០ | | ២០,០០០ |
| ៦.២.ឃ) រៀបចំការបណ្តុះបណ្តាលចាំបាច់មួយចំនួនលើប្រធានបទផ្សេងៗ | ៥០០,០០០ | | ៥០០,០០០ |
| ៦.៣.បង្កើតក្រុមពិគ្រោះយោបល់មួយ | ៤០,០០០ | | ៤០,០០០ |
| ៦.៤.ធានាការចូលរួមពីសហគមន៍និងក្រុមគ្រួសារ | | ៤០,០០០ | ៤០,០០០ |
| ៦.៥.បង្កើតមូលដ្ឋានទិន្នន័យសំរាប់អ្នកញៀនទាំងអស់ដែលបានព្យាបាល | | ២០,០០០ | ២០,០០០ |

| | | | |
|---|---|---|---|
| ៦.៦.ក) កសាងទំនាក់ទំនងរវាងមជ្ឈមណ្ឌលដូចគ្នាក្នុងតំបន់ | | ២០,០០០ | ២០,០០០ |
| ៦.៦.ខ) រៀបចំទស្សនៈកិច្ចនៅមជ្ឈមណ្ឌលដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាក្នុងតំបន់ | ៦០,០០០ | | ៦០,០០០ |
| ៦.៧.ក) បង្កើតគណៈកម្មការមូលនិធិមួយដើម្បីស្វែងរកថវិកាបន្ថែម | | ១០,០០០ | ១០,០០០ |
| ៦.៧.ខ) អនុវត្តវិធីសាស្ត្រការយកតំលៃព្យាបាលពីអ្នកញៀន | | ១០,០០០ | ១០,០០០ |
| **សរុប** | **៣.៦៤០.០០០** | **១០២.០០០** | ***៣.៧៤២.០០០*** |
| **៧. ការវាយតំលៃ** | | | |
| ៧.១. ការវាយតំលៃនៅពាក់កណ្តាលគំរោង | | ២០.០០០ | ២០.០០០ |
| ៧.២. ការវាយតំលៃនៅចុងក្រោយ | | ២០.០០០ | ២០.០០០ |
| **សរុប** | | **៤០.០០០** | ***៤០.០០០*** |
| ***សរុបរួម*** | ***៦.៤២៤.០០០*** | ***៦៨៨.០០០*** | ***៧.១១២,០០០*** |

# ពាក្យសម្ដែង

# និងអត្ថន័យពាក្យសម្ដែង

# ពាក្យសង្ខេប និងអត្ថន័យពាក្យសង្ខេប

- អ.ជ.ប.គ.ញ: អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- NACD: National Authority for Combating Drugs
  អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- UNODC: United Nation Office on Drugs and Crimes
  ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម
- JICA: Japan International Cooperation Agency
  ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន
- CLMVT: Cambodia, Lao, Myanmar, Vietnam, Thailand
  កម្ពុជា ឡាវ ភូមា វៀតណាម ថៃ
- UNAIDS: United Nation Aids
  លេខាធិការដ្ឋានទទួលបន្ទុកជម្ងឺអេដស៍របស់អង្គការសហប្រជាជាតិ
- US.CDC: United States Center for Disease Control and Prevention
  មជ្ឈមណ្ឌលរបស់សហរដ្ឋអាមេរិកសំរាប់ត្រួតពិនិត្យ និងបង្ការជម្ងឺ
- IO : International Organization
  អង្គការអន្តរជាតិ
- WHO: World Health Organization
  អង្គការសុខភាពពិភពលោក
- NGO: Non-Government Organization
  អង្គការមិនមែនរដ្ឋាភិបាល
- PAF: Project Accelerated Fund
  មូលនីធិបន្ទាន់របស់គំរោង
- BLO: Border Liaison Office
  ការិយាល័យទំនាក់ទំនងច្រកទ្វារព្រំដែន
- ATS: Amphetamine Type Stimulant
  អំហ្វេតាមីនប្រភេទលើកកំលាំង
- MOU: Memorandum Of Understanding
  អនុសារណៈនៃការយោគយល់គ្នា

- ACCORD: Asean China Cooperative Operation in Response to Dangerous Drugs កិច្ចសហប្រតិបត្តិការដោយសហការគ្នារវាងសមាជិកអាស៊ាន និងចិន ប្រឆាំងគ្រឿងញៀនដែលមានគ្រោះថ្នាក់
- CBT: Computer Base Training
  យន្តការបណ្តុះបណ្តាលតាមកុំព្យូទ័រ

# តារាងពន្យល់ពាក្យបច្ចេកទេស

# តារាងពន្យល់ពាក្យបច្ចេកទេស

| | | |
|---|---|---|
| ១.កញ្ឆា(Cannabis) | : | ជារុក្ខជាតិ( ពូជសាទីវ៉ាឬអាំងឌីកា) ដែលផ្ទុកនូវសារធាតុញៀនសំខាន់បីយ៉ាងគឺៈ<br>-តេត្រាអ៊ីដ្រូកាណាប៊ីណុល Tetra Hytro Cannabinol(THC)<br>- កាណាប៊ីណុល Cannabinol (CNB)<br>- កាណាប៊ីឌីយ៉ុល Cannabidiol(CND)<br>( សារធាតុទាំងបីនេះសំបូរនៅផ្នែកខាងចុងនៃដើមកញ្ឆា ត្រួយ ឬ ផ្កា) ។ |
| ២.ការប្រើបំពានគ្រឿងញៀន :<br>(Drug Abuse) | | ការប្រើសារធាតុញៀនខុសក្បួនវេជ្ជសាស្ត្រ ។ |
| ៣.ការកាត់បន្ថយគ្រោះថ្នាក់ :<br>(Harm Reduction) | | ការកាត់បន្ថយការឈឺចាប់ និងផលវិបាក ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន ។ |
| ៤.ការព្យាបាលនិងការស្តារនីតិសម្បទាៈ<br>(Treatment & Rehabilitation) | | ការបន្សាបជាតិញៀន ការគាំពារសុខភាព ការអប់រំ និងការផ្តល់វិជ្ជាជីវៈចំពោះអ្នកញៀនគ្រឿងញៀន ដើម្បីក្លាយជាមនុស្សមានជីវភាពធម្មតាវិញ ។ |
| ៥.ការសំអាតប្រាក់ :<br>(Money Laundering) | | ការធ្វើឱ្យប្រាក់ដែលបានមកដោយខុសច្បាប់ឱ្យទៅជាប្រាក់ស្របច្បាប់ ។ |
| ៦.ការកាត់បន្ថយតំរូវការគ្រឿងញៀន :<br>(Drug Demand Reduction) | | ការធ្វើឱ្យការប្រើបំពានគ្រឿងញៀនថយចុះតាមរយៈការបង្កើនការយល់ដឹងជាសារធារណៈដូចជា បើកសិក្ខាសាលា ផ្សាយតាម ទូរទស្សន៍ វិទ្យុ ខិតប័ណ្ណ ។ល ។ ព្រមទាំងការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។ |
| ៧.ការប្រគល់ដោយមានការឃ្លាំមើលៈ<br>(Control Delivery) | | គឺជាបច្ចេកទេសមួយនៃនីតិវិធីស៊ើបអង្កេតដែលអនុញ្ញាតអោយ មានការប្រគល់ ការលក់ ការឆ្លងកាត់ ការនាំចេញ ជាអាទិ៍ នូវគ្រឿងញៀនខុសច្បាប់ ក្នុងគោលដៅធ្វើអត្តសញ្ញាណកម្មបុគ្គលពាក់ព័ន្ធក្នុងការប្រព្រឹត្តបទល្មើសគ្រឿងញៀន ។<br><br>នីតិវិធីប្រគល់ ដោយមានការឃ្លាំមើល ត្រូវសំរេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធមិ ឬប្រតិភូដែលរដ្ឋមន្ត្រីក្រសួងយុតិធមិសំរេច តាមករណីនីមួយៗ ។ |

៨.កាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន : (Drug Supply Reduction)
- ការប្រើវិធានការណ៍នានាដើម្បីទប់ស្កាត់ ការផលិត ការដាំដុះ ការចែកចាយ ការចរាចរ និងការស្តុកទុកគ្រឿងញៀន ខុសច្បាប់ ។
- ការអភិវឌ្ឍន៍ដំណាំជំនួស

៩.ក្រុមពិគ្រោះយោបល់ : (Counseling Group)
ក្រុមជំនាញពិគ្រោះនិងផ្តល់យោបល់ចំពោះសហគមន៍ គ្រួសារ និងអ្នកប្រើបំពានគ្រឿងញៀន ។

១០.កូកាអ៊ីន(Cocaine): គឺជាសារធាតុញៀនម្យ៉ាងដែលចំរាញ់ចេញពីស្លឹកនៃដើមកូកា ។

១១.ខេត្តអាទិភាព: ខេត្តដែលកំពុងទទួលរងនូវការគំរាមកំហែងដ៏ធ្ងន់ធ្ងរនៃគ្រោះថ្នាក់គ្រឿងញៀន ។

១២.គ្រឿងញៀនសំយោគ: (Synthetic Drugs)
គឺជាគ្រឿងញៀន ដែលផលិតពីការសំយោគចេញពីសារធាតុគីមីផ្សំដោយពុំមានលាយគ្រឿងញៀនធម្មជាតិទេ ។
ប្រភេទគ្រឿងញៀនសំយោគនេះមានដូចជា អំហ្វេតាមីន មេតំហ្វេតាមីន អិកស្តាស៊ី...ដែលហៅកាត់ថា (ATS)ជាដើម ។

១៣.ត្រីកោណមាស(Golden Triangle) : តំបន់ដាំដុះដំណាំអាភៀនដ៏ធំនៅតាមបណ្តាព្រំប្រទល់ទាំងបីនៃ ប្រទេស ភូមា ថៃ ឡាវ ។

១៤.បំនិនជីវិត(Life-Skill) : ការផ្តល់មុខជំនាញឯកទេសច្បាស់លាស់ដល់អ្នកញៀនគ្រឿងញៀនដែលបានជាសះស្បើយ ។

១៥.ក្រុមប្រជាជនគោលដៅ: (Target Group)
ប្រជាជនដែលងាយរងគ្រោះដោយសារគ្រឿងញៀន ។

១៦.ពិធីសារស្តីពីការព្យាបាល : (Treatment Protocol)
ជាបែបបទណែនាំពីក្រមសីលធមិ វិជ្ជាជីវៈក្នុងការព្យាបាល តាមក្បួនវេជ្ជសាស្ត្រ និងគាំពារអ្នកញៀន ។

១៧.សមាហរណកម្ម: (Integration)
ការបញ្ចូលអ្នកញៀនគ្រឿងញៀនដែលបានជាសះស្បើយទៅក្នុងសហគមន៍វិញ ។

១៨.សារធាតុគីមីផ្សំ (Precursors) : ជាសារធាតុគីមីទាំងឡាយដែលមិនមែនជាសារធាតុញៀន( ទាំងរឹង ទាំងរាវ) ដែលត្រូវបានប្រើប្រាស់ក្នុងការផលិតគ្រឿងញៀន ហើយដែលមានចែងក្នុងតារាង៤នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

| | |
|---|---|
| ១៩.សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទៈ | ជាសារធាតុដែលអាចជះឥទ្ធិពលលើប្រព័ន្ធខួរក្បាល ខួរឆ្អឹងខ្នងរបស់មនុស្សសត្វ។ |
| ២០.ហេរ៉ូអ៊ីន(Heroine) ៖ | ជាគ្រឿងញៀនម្យ៉ាងដែលគេផលិតពីអាភៀន។ |
| ២១.អឌ្ឍច័ន្ទមាស(Golden Crescent)ៈ | តំបន់ដាំដុះដំណាំអាភៀនដ៏ធំនៃប្រទេសអាហ្វហ្គានីស្ថាន ប៉ាគីស្ថាន អ៊ីរ៉ង់ ដែលមានរាងដូចជាចំណិតព្រះខែ។ |
| ២២.អាភៀន(Opium)ៈ | គឺជាគ្រឿងញៀនធម្មជាតិម្យ៉ាង ដែលកើតចេញពីជ័រនៃផ្លែអាភៀន វាជាវត្ថុធាតុដើមសំរាប់ផលិតហេរ៉ូអ៊ីន។ |